# អង្គការសហប្រជាជាតិ
# ក្រុមប្រឹក្សាសិទ្ធិមនុស្ស

## អនុសាសន៍ស្តីពីការត្រួតពិនិត្យឡើងវិញជាសកលតាមកាលកំណត់

## ស្តីពី

## ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

*(សំរាប់ជុំទី៣)*

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

ខែសីហា ឆ្នាំ២០១៩

# អង្គការសហប្រជាជាតិ

# ក្រុមប្រឹក្សាសិទ្ធិមនុស្ស

## អនុសាសន៍ស្តីពីការត្រួតពិនិត្យឡើងវិញជាសកលតាមកាលកំណត់

# ស្តីពី

# ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

*(សំរាប់ជុំទី៣)*

# កថាមុខ

យន្តការត្រួតពិនិត្យឡើងវិញជាសកលតាមកាលកំណត់(UPR) របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស គឺជាដំណើរការតែមួយគត់ អំពីកំណត់ត្រាសិទ្ធិមនុស្សរបស់សមាជិកនីមួយៗទាំង១៩៣ប្រទេស នៃអង្គការសហប្រជាជាតិ។ ដោយមានគោលដៅខ្ពស់បំផុត ក្នុងការធ្វើឲ្យកាន់តែប្រសើរដល់ស្ថានភាពសិទ្ធិមនុស្សនៅគ្រប់រដ្ឋដែលស្ថិតនៅក្រោមការពិនិត្យ UPR ត្រូវបានបង្កើតឡើង ដើម្បីបង្កើន គាំទ្រ និងពង្រីកការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅតាមប្រទេសនីមួយៗ។ UPR គឺជាដំណើរការខិតខំប្រឹងប្រែងរបស់រដ្ឋ ដែលផ្តល់ឱកាសដល់រដ្ឋនីមួយៗ ប្រកាសពីការចាត់វិធានការនានា ដើម្បីធ្វើឲ្យប្រសើរដល់ស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស និងបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន នៅចំពោះមុខរដ្ឋដទៃទៀត និងចំពោះសាធារណៈជនទូទៅ។ UPR បង្កើតឱកាសផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋនានា និងលើកកំពស់សមត្ថភាពរបស់ពួកគេ ក្នុងការដោះស្រាយបញ្ហាប្រឈមសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាព និងចែករំលែកការអនុវត្តន៍ល្អៗ នៅក្នុងវិស័យសិទ្ធិមនុស្សរវាងរដ្ឋនានា និងដៃគូដទៃទៀត។ ជាទិដ្ឋភាពចំបងមួយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស UPR ត្រូវបានបង្កើតឡើង ដើម្បីធានាឲ្យមានការពិនិត្យដោយស្មើភាពគ្នាដល់រដ្ឋទាំងអស់ នៅពេលស្ថានភាពសិទ្ធិមនុស្សរបស់ពួកគេត្រូវបានយកមកវាយតំលៃម្តងៗ។ គ្រប់រដ្ឋត្រូវស្ថិតនៅក្រោមដំណើរការដូចគ្នា និងការត្រួតពិនិត្យដូចគ្នា ដោយមិនគិតពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សនោះទេ។ សព្វថ្ងៃនេះ មិនមានយន្តការសកលដទៃណា របៀបនេះនោះទេ។

កម្ពុជា ត្រូវបានពិនិត្យដំបូង ក្រោមដំណើរការ UPR កាលពីខែធ្នូ ឆ្នាំ២០០៩។ នៅចុងបញ្ចប់នៃការពិនិត្យលើកដំបូងរបស់ខ្លួន កម្ពុជាបានទទួលយកទាំង៩១អនុសាសន៍ ដែលធ្វើឡើងដោយរដ្ឋនានា។[១] ជុំដំបូងនៃដំណើរការ UPR បានចប់សព្វគ្រប់កាលពីខែតុលា ឆ្នាំ២០១១ នៅពេលដែលរដ្ឋសមាជិកទាំងអស់១៩៣ របស់អង្គការសហប្រជាជាតិ ត្រូវបានពិនិត្យ។ បន្ទាប់មកជុំទីពីរបានចាប់ផ្តើម ហើយកម្ពុជាត្រូវបានពិនិត្យជាថ្មីម្តងទៀត កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤។ គ្រប់ទិន្នន័យព័ត៌មាន ត្រូវបានដាក់ចូលសំរាប់ការត្រួតពិនិត្យលើកទី២នេះ រួមមានរបាយការណ៍ជាតិរបស់រាជរដ្ឋាភិបាល និងកម្រងព័ត៌មានពីយន្តការសិទ្ធិមនុស្សសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ហើយព័ត៌មានទាំងនេះ សុទ្ធតែអាចរកបាននៅក្នុងគេហទំព័ររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។[២] កិច្ចសន្ទនានៃការត្រួតពិនិត្យនេះ ក៏អាចរកមើលផងដែរនៅក្នុងគេហទំព័រនេះ។[៣]

*១. អនុសាសន៍ទាំងនេះ អាចរកបាននៅគេហទំព័រ៖* http://www.ohchr.org/EN/HRBodies/UPR/Pages/KHSession6.aspx

*២. ឯកសារទាំងនេះអាចរកបាននៅគេហទំព័រ* http://www.ohchr.org/EN/HRBodies/UPR/Pages/KHSession18.aspx. *ដើម្បីរកមើលការដាក់ឯកសាររបស់អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារសហប្រជាជាតិនីមួយៗ សូមចុចលើរឹមទំព័រនៃគេហទំព័រនោះ។*

*៣. សូមមើលគេហទំព័រ៖* http://webtv.un.org/watch/cambodia-review-18th-session-of-universal-periodic-view/3119784522001/

នៅក្នុងជុំទី៣នេះ កម្ពុជាត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យនៅថ្ងៃទី៣០ មករា ឆ្នាំ២០១៩ ហើយមានអនុសាសន៍ចំនួន១៩៨ បានដាក់ជូនកម្ពុជា ដែលត្រូវបោះពុម្ពផ្សាយនៅក្នុងសៀវភៅនេះ។ ក្នុងកំឡុងពេលពិនិត្យកាលពីខែមករា កម្ពុជាបានទទួលយកអនុសាសន៍ចំនួន១៧៣ ហើយបានសុំពន្យាពេលធ្វើសេចក្តីសំរេចលើអនុសាសន៍ដែលនៅសេសសល់ចំនួន២៥ រហូតដល់សម័យប្រជុំខែកក្កដា របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ កម្ពុជាបានប្រកាសពីជំហរចុងក្រោយរបស់ខ្លួនថា ខ្លួនព្រមទទួលយកតែ១៧៣អនុសាសន៍ប៉ុណ្ណោះ និងសូមធ្វើការកត់សំគាល់ចំពោះអនុសាសន៍ដែលនៅសេសសល់ចំនួន២៥ទៀត។ អនុសាសន៍ UPR បង្ហាញនូវការវាយតំលៃជារួមមួយអំពីតថភាពនៃកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា ព្រមទាំងចំណុចឆកល្វែង និងឱកាសពាក់ព័ន្ធនានា ដើម្បីពង្រឹងដល់កិច្ចការពារនេះ។

ដើម្បីបង្ហាញពីការរីកចំរើននៅជុំបន្ទាប់នៃUPR ដែលនឹងត្រូវប្រព្រឹត្តទៅក្នុងរវាង៤ឆ្នាំទៀត រដ្ឋាភិបាល នឹងត្រូវចាត់វិធានការជាក់ស្តែងភ្លាមៗ ឆ្ពោះទៅរកការអនុវត្តន៍អនុសាសន៍ទាំងនេះ។ ការអនុវត្តន៍ដ៏មានអត្ថន័យ និងមានការឯកភាពគ្នា នៃអនុសាសន៍UPR ត្រូវធានាថា រាល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល អង្គការសង្គមស៊ីវិល ទីភ្នាក់ងារសហប្រជាជាតិ និងសហគមន៍អន្តរជាតិ ព្រមទាំងដៃគូចូលរួមដទៃទៀត នឹងឆ្ពោះទៅរកការរីកចំរើនដ៏មានអត្ថន័យ។ កិច្ចខិតខំប្រឹងប្រែងបែបនេះ នឹងរួមចំណែកដល់ការអនុវត្តន៍អនុសាសន៍នានា ដែលបានដាក់ចេញកាលពីមុនៗ ដោយស្ថាប័នសន្ធិសញ្ញា និងយន្តការសិទ្ធិមនុស្សដទៃទៀត ដូចជាអ្នករាយការណ៍ពិសេសអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាជាដើម ដែលអនុសាសន៍ទាំងនោះភាគច្រើន មានឆ្លុះបញ្ចាំងនៅក្នុងអនុសាសន៍ UPR ។ ការអនុវត្តន៍ដ៏ជោគជ័យ នឹងជួយដល់ការព្រាងរបាយការណ៍បន្ទាប់របស់ UPR កាន់តែមានភាពងាយស្រួល។

ដើម្បីសំរេចបានគោលបំណងនេះ ជាសំខាន់រដ្ឋត្រូវកំណត់ពីស្ថាប័នជាក់លាក់នានារបស់ខ្លួន ដើម្បីទទួលខុសត្រូវក្នុងការអនុវត្តន៍អនុសាសន៍តាមវិស័យជាក់លាក់រៀងៗខ្លួន។ កិច្ចការត្រូវចាប់ផ្តើមភ្លាមៗ ដើម្បីកំណត់ ក)បញ្ហានានាដែលពាក់ព័ន្ធ ខ)អាជ្ញាធរទទួលខុសត្រូវ និងគ)ការចាត់វិធានការជាក់លាក់ដើម្បីអនុវត្តអនុសាសន៍។ ជាសំខាន់ត្រូវរំលឹកថា ការទទួលខុសត្រូវក្នុងការចាត់វិធានការ មិនមែនអាស្រ័យទាំងស្រុងលើអំណាចនីតិប្រតិបត្តិនោះទេ។ មានអនុសាសន៍ខ្លះតម្រូវឲ្យមានការអនុម័ត ឬការកែសម្រួលច្បាប់ ជាឧទាហរណ៍ គឺសភា នឹងត្រូវដើរតួនាទីយ៉ាងសំខាន់នេះ។

ទិដ្ឋភាពតែមួយគត់នៃដំណើរការUPR គឺថា វាឆ្លុះបញ្ចាំងនូវការប្រមូលផ្តុំនៃទស្សនៈអន្តរជាតិអំពីស្ថានភាពសិទ្ធិមនុស្ស នៅតាមប្រទេសនីមួយៗដែលស្ថិតក្រោមការពិនិត្យ ហើយអនុសាសន៍

ដែលជាលទ្ធផលពីការពិនិត្យនេះ ត្រូវបានទទួលយកដោយស្ម័គ្រចិត្ត និងជាសាធារណៈដោយរដ្ឋដែលស្ថិតក្រោមការពិនិត្យ។ ដូច្នេះ អនុសាសន៍ទាំងនេះ អាចក្លាយជាឧបករណ៍នៃការតស៊ូមតិដ៏មានអំណាចបំផុត សំរាប់ដៃគូពាក់ព័ន្ធទាំងអស់។ អនុសាសន៍នីមួយៗ គួរបរិយាយនៅក្នុងផែនការជាក់ស្តែង ដើម្បីអនុវត្ត ឬគាំទ្រការអនុវត្តន៍អនុសាសន៍ UPR។ ការទទួលខុសត្រូវក្នុងការអនុវត្តន៍អនុសាសន៍ UPR ជាការពិតហើយ ជារបស់រដ្ឋាភិបាល ក៏ប៉ុន្តែសង្គមស៊ីវិល ក៏អាច និងគួរដើរតួសំខាន់ក្នុងការជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលនៅក្នុងវិស័យនេះដែរ។ សង្គមស៊ីវិល ក៏ដើរតួនាទីសំខាន់ផងដែរ ក្នុងការតាមឃ្លាំមើលស្ថានភាពនៃការអនុវត្តន៍អនុសាសន៍ទាំងនេះ។

រួមជាមួយអនុសាសន៍នានារបស់យន្តការជំនាញ ដូចជាគណៈកម្មាធិការឃ្លាំមើលសន្ធិសញ្ញា និងអ្នករាយការណ៍ពិសេសនានា អនុសាសន៍ UPR ថ្លែងពីបញ្ហានានា ដែលមានលក្ខណៈទូលំទូលាយ គ្របដណ្តប់លើវិស័យនានា ដែលក្នុងនោះ ទីភ្នាក់ងារសហប្រជាជាតិ ជារឿយៗតែងផ្តល់ការគាំទ្រដល់រដ្ឋាភិបាល។ ក្នុងករណីនេះ ដោយទទួលយកការណែនាំពីអនុសាសន៍ទាំងនេះ ទីភ្នាក់ងារសហប្រជាជាតិ អាចផ្តល់ជំនួយដ៏មានសារៈសំខាន់ ដល់ការអនុវត្តន៍ UPR នៅក្នុងវិស័យជាក់លាក់ដែលខ្លួនមានសមត្ថកិច្ច។

អនុសាសន៍ពីគ្រប់យន្តការសិទ្ធិមនុស្សអាចប្រើជាកាតាលីករ—ហើយធ្លាប់បានអនុវត្តបែបនេះនៅតាមបណ្តាប្រទេសជាច្រើន—សំរាប់រដ្ឋាភិបាល សង្គមស៊ីវិល សហគមន៍អន្តរជាតិ និងប្រព័ន្ធសហប្រជាជាតិ ចូលរួមប្រឹងប្រែងក្នុងការអនុវត្តអនុសាសន៍ទាំងនេះ ដើម្បីធ្វើឲ្យកិច្ចការពារសិទ្ធិមនុស្សកាន់តែប្រសើរ។ ឱកាសអនុវត្តដូចគ្នាបែបនេះនៅកម្ពុជា មិនគួរត្រូវបានបោះបង់ឡើយ។ ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូជាច្រើន ដែលបានយកចិត្តយ៉ាងជ្រាលជ្រៅ ដល់ការលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ត្រៀមខ្លួនជាស្រេចដើម្បីចូលរួមក្នុងការអនុវត្តអនុសាសន៍ទាំងនេះ ជាមួយពួកគេ ដោយឆ្លៀតយកប្រយោជន៍ពីការបើកជាថ្មីដល់កំណែទម្រង់ដ៏ទាន់ពេល ដើម្បីចាប់ផ្តើមដំណើរការអនុវត្ត UPR នេះ ដោយម៉ឺងម៉ាត់។ ការិយាល័យឧត្តមស្នងការ បានជួយដល់ការបោះពុម្ពនេះ ថាជាជំហានដំបូងនៅក្នុងទិសដៅនេះ។ នេះគឺជាការឧទ្ទិសដល់ប្រជាជនកម្ពុជា និងអ្នកទាំងឡាយណាដែលចូលរួមការពារសិទ្ធិមនុស្សរបស់ពួកគេ។

*លោកសាយម៉ុន វ៉េកខឺរ*

*តំណាងស្តីទី*

*ការិយាល័យ* OHCHR-Cambodia

ខែសីហា ឆ្នាំ២០១៩

# អំពីដំណើរការ UPR

ការត្រួតពិនិត្យ ត្រូវបានធ្វើឡើងរៀងរាល់៤.៥ ឆ្នាំម្តង ដោយក្រុមការងារ UPR ដែលមានសមាជិកចំនួន៤៧រដ្ឋ នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ទោះបីជារដ្ឋសមាជិកណាមួយរបស់អង្គការសហប្រជាជាតិ អាចចូលរួមក្នុងកិច្ចពិភាក្សា/សន្ទនា ជាមួយរដ្ឋដែលស្ថិតនៅក្រោមការពិនិត្យក៏ដោយ។ រដ្ឋនីមួយៗដែលស្ថិតក្រោមការពិនិត្យ ត្រូវបានជួយដោយក្រុមនៃរដ្ឋបី ដែលដឹងថាជា "troikas" ធ្វើជាអ្នករាយការណ៍។ ការជ្រើសរើស troikas សំរាប់រដ្ឋនីមួយៗ ត្រូវធ្វើតាមរយៈការចាប់ឆ្នោត បន្ទាប់ពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ។

ការត្រួតពិនិត្យនេះ ផ្អែកលើឯកសារបី៖

១. ព័ត៌មានដែលផ្តល់ឲ្យដោយរដ្ឋដែលស្ថិតក្រោមការពិនិត្យ ដែលអាចធ្វើតាមទម្រង់ជា "របាយការណ៍ជាតិ"។

២. ព័ត៌មានដែលមាននៅក្នុងរបាយការណ៍របស់អ្នកជំនាញការ និងក្រុមឯករាជ្យខាងសិទ្ធិមនុស្ស រួមមាននីតិវិធីពិសេស ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងស្ថាប័នសហប្រជាជាតិដទៃទៀត។

៣. ព័ត៌មានពីដៃគូដទៃទៀតរួមមានស្ថាប័នសិទ្ធិមនុស្សជាតិនិងអង្គការមិនមែនរដ្ឋាភិបាល។

UPR នឹងវាយតំលៃពីវិសាលភាពដែលរដ្ឋគោរពកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួនដូចមានចែងក្នុង (១)ធម្មនុញ្ញសហប្រជាជាតិ (២)សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (៣)លិខិតុបករណ៍សិទ្ធិមនុស្សដែលរដ្ឋនោះជាភាគី (សន្ធិសញ្ញាសិទ្ធិមនុស្សនានាដែលរដ្ឋនោះបានផ្តល់សច្ចាប័ន) (៤) ការសន្យា និងការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តធ្វើដោយរដ្ឋនោះចំពោះសហគមន៍អន្តរជាតិ (ឧ. គោលនយោបាយសិទ្ធិមនុស្សជាតិ និង/ឬកម្មវិធីនានាដែលត្រូវអនុវត្ត) និង(៥)ច្បាប់មនុស្សធម៌អន្តរជាតិដែលនៅជាធរមាន។

ការត្រួតពិនិត្យ ប្រព្រឹត្តទៅតាមរយៈកិច្ចសន្ទនាគ្នាជាអន្តរកម្មរវាងរដ្ឋស្ថិតនៅក្រោមការពិនិត្យ និងសមាជិកដទៃទៀតរបស់សហប្រជាជាតិ។ កិច្ចនេះប្រព្រឹត្តទៅក្នុងកំឡុងពេលកិច្ចប្រជុំរបស់ក្រុមការងារ UPR។ ក្នុងកំឡុងពេលពិភាក្សាគ្នានេះ សមាជិកណាក៏ដោយរបស់អង្គការសហប្រជាជាតិ អាចតាំងសំណួរ យោបល់ និង/ឬធ្វើអនុសាសន៍ដល់រដ្ឋដែលស្ថិតនៅក្រោមការពិនិត្យ។ រយៈពេលនៃការត្រួតពិនិត្យ គឺ៣ម៉ោង និង៣០នាទី។

បន្ទាប់ពីការត្រួតពិនិត្យដោយក្រុមការងារ troika នឹងរៀបចំរបាយការណ៍មួយ ដោយមានការចូលរួមពីរដ្ឋដែលស្ថិតក្រោមការពិនិត្យ និងជំនួយពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។ របាយការណ៍នេះដែលត្រូវទុកជា "របាយការណ៍លទ្ធផល" រៀបរាប់យ៉ាងសង្ខេបពីកិច្ចសន្ទនាគ្នានោះ។ ដូច្នេះ របាយការណ៍នេះ មានសំណួរ យោបល់ និងអនុសាសន៍ដែលដាក់ដោយរដ្ឋនានាដល់រដ្ឋដែលស្ថិតក្រោមការពិនិត្យ ព្រមទាំងការឆ្លើយតបរបស់រដ្ឋដែលស្ថិតក្រោមការពិនិត្យ។

ពេលវេលាត្រូវបានផ្តល់ឲ្យក្រុមការងារដើម្បីអនុម័ត "របាយការណ៍លទ្ធផល" នីមួយៗរបស់រដ្ឋដែលស្ថិតក្រោមការពិនិត្យ ក្នុងកំឡុងសម័យប្រជុំនោះ។ រដ្ឋដែលស្ថិតក្រោមការពិនិត្យ មានឱកាសផ្តល់យោបល់បឋម ទៅលើអនុសាសន៍នានា ជ្រើសរើសថាព្រមទទួលយក ឬគ្រាន់តែធ្វើការកត់សំគាល់លើអនុសាសន៍ទាំងនោះ។ ទាំងអនុសាសន៍ដែលបានទទួលយក និងអនុសាសន៍ដែលគ្រាន់តែធ្វើការកត់សំគាល់ ត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍នេះ។

បន្ទាប់មក របាយការណ៍នេះ ត្រូវដាក់ជូនសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សដើម្បីទទួលការអនុម័ត។ នៅពេលនោះ រដ្ឋដែលស្ថិតក្រោមការពិនិត្យអាចឆ្លើយទៅនឹងសំណួរ និងបញ្ហានានាដែលមិនទាន់បានឆ្លើយគ្រប់គ្រាន់នៅកំឡុងពេលក្រុមការងារ និងឆ្លើយតបចំពោះអនុសាសន៍ដែលត្រូវបានលើកឡើងដោយរដ្ឋនានាក្នុងកំឡុងពេលនៃការត្រួតពិនិត្យ។ ពេលវេលាក៏មានផ្តល់ជូនរដ្ឋសមាជិក និងរដ្ឋសង្កេតការណ៍ដែរ ដែលចង់សំដែងមតិរបស់ខ្លួន អំពីលទ្ធផលនៃការត្រួតពិនិត្យនេះ និងក៏មានផ្តល់ជូនស្ថាប័នសិទ្ធិមនុស្សជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូដទៃទៀត ដើម្បីផ្តល់យោបល់ជាទូទៅដែរ។

រដ្ឋដែលស្ថិតក្រោមការពិនិត្យ តែងតែមានការទទួលខុសត្រូវបឋម ដើម្បីអនុវត្តអនុសាសន៍នានាដែលមាននៅក្នុងរបាយការណ៍លទ្ធផលចុងក្រោយ។ UPR ធានាថា គ្រប់ប្រទេស ត្រូវទទួលខុសត្រូវចំពោះការរីកចំរើន ឬការខកខានក្នុងការអនុវត្តអនុសាសន៍ទាំងនេះ។ ក្នុងកំឡុងការត្រួតពិនិត្យលើកក្រោយ រដ្ឋត្រូវបានរំពឹងថា នឹងផ្តល់ព័ត៌មានអំពីវិធានការនានាដែលខ្លួនបានចាត់ឡើងដើម្បីអនុវត្តអនុសាសន៍នានាដែលបានផ្តល់ឲ្យកាលពីលើកមុន ព្រមទាំងអំពីការវិវត្តន៍ណាមួយនៅក្នុងវិស័យសិទ្ធិមនុស្ស។ សហគមន៍អន្តរជាតិ មានតួនាទីជួយអនុវត្តអនុសាសន៍ទាំងនេះ តាមរយៈការផ្តល់ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព ដោយពិគ្រោះយោបល់ជាមួយរដ្ឋសាមី។

# របាយការណ៍របស់ក្រុមការងារអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់

(A/HRC/WG.6/32/L.14 , 1 February 2019)

ក្រុមប្រឹក្សាសិទ្ធិមនុស្ស

ក្រុមការងារអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់

សម័យប្រជុំលើកទី៣២

ទីក្រុងហ្សឺណែវ ចាប់ពីថ្ងៃទី២១ ខែមករា ដល់ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៩

# កម្ពុជា

## សេចក្តីផ្តើម

1. ក្រុមការងារអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR) ដែលត្រូវបានបង្កើតឡើង ស្របតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ៥/១ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ ២០០៧ បានបើកសម័យប្រជុំលើកទី៣២ របស់ខ្លួន ពីថ្ងៃទី២១ ខែមករា ដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩។ ការពិនិត្យឡើងវិញនៃប្រទេសកម្ពុជា ត្រូវបានធ្វើឡើងនៅឯកិច្ចប្រជុំទី១៦ ចំថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៩។ គណៈប្រតិភូកម្ពុជាដឹកនាំដោយ ឯ.ឧ.កែវ រ៉េមី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ នៅឯកិច្ចប្រជុំលើកទី១៨របស់ខ្លួនដែលបានធ្វើឡើងនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០១៩ ក្រុមការងារនេះបានអនុម័តរបាយការណ៍អំពីកម្ពុជា។

2. នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានជ្រើសរើសក្រុមអ្នករាយការណ៍ (ក្រុមបីប្រទេស) ដូចខាងក្រោម ដើម្បីសម្របសម្រួលដល់ការពិនិត្យឡើងវិញលើប្រទេសកម្ពុជា៖ ប្រទេសសេណេហ្គាល ប៉ាគីស្ថាន និងចក្រភពអង់គ្លេស។

3. ស្របតាមវាក្យខណ្ឌទី១៥ នៃឧបសម្ព័ន្ធភ្ជាប់នឹងសេចក្តីសំរេចលេខ៥/១ និងវាក្យខណ្ឌទី ៥ នៃឧបសម្ព័ន្ធភ្ជាប់នឹងសេចក្តីសម្រេចលេខ១៦/២១ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ឯកសារទាំងឡាយដូចខាងក្រោមនេះ ត្រូវបានដាក់ចេញដល់ការពិនិត្យឡើងវិញសំរាប់ប្រទេសកម្ពុជា៖

(a) របាយការណ៍ជាតិមួយដែលត្រូវបានបញ្ជូនមក/បង្ហាញមកជាលាយលក្ខណ៍អក្សរស្របតាមវាក្យខណ្ឌទី១៥(a) (A/HRC/WG.6/32/KHM/1);

(b) កម្រងឯកសារមួយដែលចងក្រងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស ស្របតាមវាក្យខណ្ឌទី១៥(b) (A/HRC/WG.6/32/KHM/2);

(c) សេចក្តីសង្ខេបមួយដែលរៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សស្របតាមវាក្យខណ្ឌទី១៥(c) (A/HRC/WG.6/32/KHM/3 and corr.1)។

4. បញ្ជីសំណួរមួយដែលបានរៀបចំរួចជាមុនដោយប្រទេសអូស្ត្រាលី បែលហ្ស៊ិក លីឆតេនស្តេន ព័រទុយហ្គេក្នុងនាមក្រុមប្រទេសជាមិត្តពីការអនុវត្តន៍ ការរាយការណ៍ និងការតាមដានអនុវត្តនៅថ្នាក់ជាតិ ប្រទេសស្លូវ៉ានី អេស្ប៉ាញ និងសហរដ្ឋអាមេរិក ត្រូវបានបញ្ជូនមកកម្ពុជា តាមរយៈក្រុមបីប្រទេស(troika)។ សំណួរទាំងនេះ មាននៅគេហទំព័ររបស់ UPR។

# I. សង្ខេបនីតិវិធីនៃដំណើរការពិនិត្យឡើងវិញ

## ក. បទបង្ហាញដោយរដ្ឋដែលស្ថិតក្រោមការពិនិត្យឡើងវិញ

5. កម្ពុជា បានកំពុងងើបចេញពីកេរតំណែលនៃការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ហើយជាការពិតទៅ ឆ្នាំ២០១៩ បានសំគាល់ពីខួបលើកទី៤០ នៃការរំដោះប្រទេសចេញពីរបបប្រល័យពូជសាសន៍ប៉ុល ពត។ ជាលទ្ធផល ការធ្វើឱ្យសម្រេចបាននូវសិទ្ធិមនុស្សជាមូលដ្ឋាន ដែលប្រជាពលរដ្ឋគ្រប់រូបត្រូវទទួលបាន នៅតែជាកិច្ចការដំបូង និងសំខាន់បំផុតរបស់រដ្ឋាភិបាល។

6. ជាប្រទេសមិនទាន់អភិវឌ្ឍន៍ ជាប់ផុងនឹងភាពក្រីក្រ និងអសន្តិសុខស្បៀងកាលពីមុន តលូវនេះកម្ពុជាបានក្លាយខ្លួនជាប្រទេសនាំចេញស្បៀងអាហារ គឺជាប្រទេសមួយដែលមានសេដ្ឋកិច្ចលូតលាស់លឿនជាងគេនៅក្នុងពិភពលោក និងជាអ្នកបំពេញកាតព្វកិច្ចគួរឱ្យកត់សំគាល់ក្នុងការកាត់បន្ថយភាពក្រីក្រ និងការធ្វើឱ្យកាន់តែប្រសើរនៅក្នុងសូចនាករសង្គម។ កម្ពុជាបានធ្វើឱ្យមានការរីកចំរើនគួរឱ្យកត់សំគាល់ក្នុងការទទួលបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ ចាប់តាំងពីឆ្នាំ១៩៩០មក ប្រទេសនេះបានសម្រេចជាងពាក់កណ្តាលពីភាពក្រីក្របំផុត និងមរណៈភាពមាតា បានសម្រេចស្ទើរតែទាំងស្រុងនូវការចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សា និងធ្វើឱ្យមានការរីកចំរើនជាច្រើនក្នុងការប្រយុទ្ធប្រឆាំងនឹងហ៊ីវ-អេដស៍។ កម្ពុជាបានរីកលូតលាស់នៅអាត្រាជាមធ្យម ៧% ក្នុងកំឡុងពេល២ទស្សវត្សចុងក្រោយនេះ ហើយបានក្លាយជាប្រទេសដែលសេដ្ឋកិច្ចមានចំណូលមធ្យមទាបនៅឆ្នាំ២០១៦។ កម្ពុជានឹងប្រហែលលែងស្ថិតនៅជាប្រទេសមិនអភិវឌ្ឍន៍ទៀតហើយ ចាប់ពីឆ្នាំ២០២៥ ប្រសិនបើកម្ពុជានៅតែបន្តអាត្រាកំណើនដូចសព្វថ្ងៃ។

7. កម្ពុជាបានចូលរួមជាមួយយន្តការសិទ្ធិមនុស្សជាច្រើន ក្នុងការការពារ និងការលើកកំពស់សិទ្ធិមនុស្ស ដូចដែលបានឃើញពីវត្តមាននៅតែបន្តរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការចូលរួមរបស់រដ្ឋនៅក្នុងយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងរបាយការណ៍របស់ខ្លួនជាច្រើនទៀតទៅស្ថាប័នសន្ធិសញ្ញា។ កម្ពុជាគឺជារដ្ឋភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សស្នូលចំនួន៨ ដែលខ្លួនបានផ្តល់សច្ចាប័នដោយគ្មានការដាក់ខលក្ខខណ្ឌឡើយ។ កម្ពុជា គឺជាប្រទេសតែមួយគត់នៅអាស៊ី ដែលអនុញ្ញាតិឱ្យមានការិយាល័យ OHCHR នៅក្នុងប្រទេសរបស់ខ្លួន។

8. ទាក់ទងនឹងការតាមដានអនុវត្តន៍អនុសាសន៍ចំនួន១៦២ ដែលខ្លួនបានទទួលយកកាលពីជុំទី២នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្នុងនាមជាទីភ្នាក់ងារមួយរបស់រដ្ឋាភិបាល បានសហការជាមួយការិយាល័យ OHCHR ដើម្បីចងក្រងអនុសាសន៍ទាំងនេះ និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយអនុសាសន៍ទាំងនេះ ដល់ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់របស់រដ្ឋាភិបាលដើម្បីយកទៅអនុវត្តន៍។ គណៈកម្មាធិការ ក៏បានធ្វើការតាមដានការអនុវត្តន៍ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងបានទទួលយោបល់ត្រឡប់ពីការសម្រេចបានសមិទ្ធផលរបស់ក្រសួងស្ថាប័នទាំងនោះ ដែលត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍រដ្ឋសំរាប់ជុំទី៣នៃការត្រួតពិនិត្យ UPR នេះ។ ការងាររៀបចំព្រាងរបាយការណ៍ជាតិត្រូវបានអនុវត្តន៍ដោយគណៈកម្មាធិការ ដោយមានកិច្ចពិគ្រោះយោបល់យ៉ាងជិតស្និទជាមួយក្រសួងស្ថាប័នរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងការិយាល័យ OHCHR នៅកម្ពុជា។

9. ការបោះឆ្នោតសំរាប់នីតិកាលលើកទី៦នៃរដ្ឋសភា កាលពីថ្ងៃ២៩ ខែកក្កដា ឆ្នាំ២០១៨ ត្រូវបានរៀបចំឡើងតាមលក្ខណៈសេរី ត្រឹមត្រូវ និងមានតម្លាភាព។ គណៈបក្សនយោបាយសរុបចំនួន២០បានចុះបញ្ជីចូលរួមប្រកួតប្រជែងការបោះឆ្នោត ហើយអ្នកបោះឆ្នោតដែលបានចុះឈ្មោះចំនួន៨៣.០២ភាគរយ បានទៅបោះឆ្នោតសំដែងពីបំណងប្រាថ្នារបស់ខ្លួនចង់ឃើញពីការបន្តក្នុងផ្លូវរក្សាសន្តិភាព ស្ថេរភាព ប្រជាធិបតេយ្យ និងនីតិរដ្ឋរបស់ប្រទេស។

10. ចំណាត់ការតាមផ្លូវច្បាប់ប្រឆាំងនឹងគណៈបក្សនយោបាយណាមួយ ដែលបានបំពានច្បាប់ គឺជាដំណើរការធម្មតានៃលទ្ធិប្រជាធិបតេយ្យ នៅក្នុងរដ្ឋប្រជាធិបតេយ្យណាក៏ដោយ ដែលប្រកាន់ខ្ជាប់នូវគោលការណ៍នីតិរដ្ឋ និងសំដៅពង្រឹងដំណើរការប្រជាធិបតេយ្យ និងថែរក្សាសន្តិភាព និងស្ថេរភាពដែលជាមូលដ្ឋានដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងរយៈពេលយូរអង្វែង និងប្រកបដោយចេរភាព។

11. ការអនុវត្តន៍វិធីសាស្រ្តបែងចែកអាសនៈ ដែលបានអនុម័តកាលពីឆ្នាំ២០១៤ ដែលត្រូវបានផ្តល់សុពលភាពនៅពេលនោះដោយគណៈបក្សប្រឆាំង បាននាំឱ្យគណៈបក្សប្រជាជនកម្ពុជាឈ្នះទាំង១២៥អាសនៈនៅសភា ជាមួយនឹងសំលេង៧៦.៧៨% នៃសន្លឹកឆ្នោតដែលបានបោះ។ ទោះបីយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានបង្កើតយន្តការពិគ្រោះយោបល់ដែលមានការចូលរួមមួយ ដោយមានការចូលរួមពីគ្រប់គណៈបក្សនយោបាយ ដែលត្រូវបានស្គាល់ថាជា ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ដើម្បីប្រមូលធាតុចូលសំរាប់ជាប្រយោជន៍ដល់ការកសាងជាតិ។ ក្រុមប្រឹក្សានេះបានផ្តល់ឱ្យមានវេទិកាពិគ្រោះយោបល់ជាសាធារណៈសំរាប់ការបង្កើត និងការអនុវត្តន៍ច្បាប់និងគោលនយោបាយ និងជាវេទិកាមួយសំរាប់ផ្ទៀងផ្ទាត់តុល្យភាព checks-and-balances ជាមួយរដ្ឋាភិបាល។

12. រដ្ឋាភិបាលក៏បានអំពាវនាវដល់ប្រព័ន្ធតុលាការ ដែលជាស្ថាប័នឯករាជ្យនោះ ឱ្យពន្លឿននីតិវិធីសវនាការសកម្មជន និងអ្នកដឹកនាំសហជីពដែលជាប់បណ្តឹង ឬត្រូវបានចោទប្រកាន់ ស្របតាមនីតិវិធីតុលាការសព្វថ្ងៃដើម្បីការពារសិទ្ធិរបស់ពួកគេដូចត្រូវបានធានាការពារតាមរដ្ឋធម្មនុញ្ញ។

13. រដ្ឋាភិបាល ក៏បានលើកកំពស់ភាពជាដៃគូពិតប្រាកដជាមួយអង្គការសង្គមស៊ីវិល ក្នុងគ្រប់វិស័យនៃការអភិវឌ្ឍន៍សង្គម។ រដ្ឋាភិបាលបានបង្កើតក្រុមការងារមួយកាលពីពេលថ្មីៗនេះក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ ដើម្បីពិគ្រោះយោបល់ជាទៀងទាត់ជាមួយសង្គមស៊ីវិល។ វេទិកាលើកទី២ អំពីភាពជាដៃគូរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដែលប្រព្រឹត្តិទៅនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ មានការចូលរួមពីរាប់រយអង្គការដោយគ្មានការរើសអើង បើកឱ្យមានកិច្ចពិភាក្សាបែបស្ថាបនា បាននាំឱ្យមានវិធានការជាក់ស្តែងនានា ដើម្បីជួយសម្រួលដល់សកម្មភាពរបស់អង្គការទាំងនោះ។ វេទិកាពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការបរទេស ត្រូវបានរៀបចំកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ ដោយក្រសួងការបរទេស។ វេទិកាដែលមានលក្ខណៈសហការ និងបរិយាប័ន្នបែបនេះ មានបំណងកែលំអការយោគយល់គ្នាលើបញ្ហាផ្សេងៗនៅជុំវិញការអនុវត្តន៍ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ដទៃទៀតទាក់ទងនឹងអង្គការសង្គមស៊ីវិល។

14. ពាក់ព័ន្ធនឹងសិទ្ធិការងារ និងសហជីព រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិមួយដើម្បីពិនិត្យឡើងវិញលើអនុសញ្ញាអន្តរជាតិដែលកម្ពុជាបានផ្តល់សច្ចាប័ន ដើម្បីពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធ និងអង្គការពលកម្មអន្តរជាតិ។

15. ក្នុងខែមករា ឆ្នាំ២០១៩ ប្រាក់ឈ្នួលអប្បបរមាសំរាប់កម្មករនៅក្នុងវិស័យវាយនភ័ណ្ឌ រោងចក្រកាត់ដេរ និងឧស្សាហកម្មស្បែកជើង បានកើនដល់១៨២ដុល្លា កើនឡើងពី១៧០ដុល្លា កាលពីឆ្នាំមុន។ តាមពិតទៅ ប្រាក់ឈ្នួលបានកើនឡើងច្រើនជាងទ្វេដងចាប់តាំងពីឆ្នាំ២០១៣។ កំរិតជាប់ពន្ធលើប្រាក់ចំណូលត្រូវបានកើនឡើងដល់៣០០ដុល្លាក្នុងមួយខែ ដើម្បីធានាថា ប្រាក់ឈ្នួលថ្មីដែលទទួលបានមិនត្រូវជាប់ពន្ធ។ អត្ថប្រយោជន៍ និងប្រាក់ឧបត្ថម្ភដែលមិនមែនជាប្រាក់បៀវត្ស ដែលកម្មករទទួលបាន នឹងនៅបន្តរក្សាឱ្យផុតពីការគណនាកំរិតជាប់ពន្ធដដែល។

16. ឥលូវនេះនិយោជកតម្រូវឱ្យបង់៣.៤%នៃប្រាក់ខែនិយោជិកម្នាក់ៗចូលទៅក្នុងមូលនីធិបេឡាជាតិសន្តិសុខសង្គម សំរាប់ការថែទាំសុខភាព និងការធានារ៉ាប់រងសំរាប់គ្រោះថ្នាក់ការងារ។ ប្រាក់សោធននិវត្តន៍សំរាប់កម្មករក្នុងវិស័យកាត់ដេរ ក៏ត្រូវបានប្រកាសឱ្យមានផងដែរ នៅក្នុងឆ្នាំ២០១៩នេះ។ កម្មការិនី មានសិទ្ធិឈប់សំរាកមាតុភាពរយៈពេល៣ខែ ជាមួយនឹងប្រាក់បៀវត្ស ១២០%នៃប្រាក់ខែរបស់ខ្លួន (សមមូលនឹង៧០% នៃប្រាក់ខែរបស់ខ្លួន រ៉ាប់រងដោយបេឡាជាតិសន្តិសុខសង្គម ហើយ៥០%ទៀត រ៉ាប់រងដោយនិយោជក)។

17. ទាក់ទងនឹងសេរីភាពសារព័ត៌មាននិងសេរីភាពនៃការសំដែងមតិ កាសែត the *Cambodia Daily* ត្រូវបានបិទដោយសារតែការខកខានរបស់ខ្លួនក្នុងការបំពេញតាមកាតព្វកិច្ចពន្ធ ស្របតាមច្បាប់ពន្ធដារ។ ក្នុងករណីដែលកាសែតនេះបានបំពេញតាមកាតព្វកិច្ចពន្ធត្រឹមត្រូវតាមផ្លូវច្បាប់ នោះកាសែតនេះអាចដំណើរការប្រតិបត្តិការរបស់ខ្លួនឡើងវិញ។ ការបិទការិយាល័យវិទ្យុអាស៊ីសេរី(RFA) និងសំលេងសហរដ្ឋអាមេរិក(VOA) គឺជាការបិទដោយឯកឯង។ ស្ថានីយ៍វិទ្យុទាំងពីរនេះ អាចបើកឡើងវិញដោយសេរីនូវការិយាល័យរបស់ខ្លួន។ រដ្ឋាភិបាលក៏ធ្វើការផងដែរលើក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ ហើយមានការប្តេជ្ញាខ្ពស់ ដើម្បីបង្កើយសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន រួមជាមួយច្បាប់សំខាន់ពីរទៀតគឺ ច្បាប់ប្រឆាំងឧក្រិដ្ឋកម្មព័ត៌មានវិទ្យា និងការធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន។

18. អំពីបញ្ហាដីធ្លី រដ្ឋាភិបាលបានណែនាំឱ្យអនុវត្តន៍គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ គ្រប់គ្រងវិស័យដីធ្លី ដើម្បីធានាពីសិទ្ធិ និងផលប្រយោជន៍របស់ប្រជាជន និងការប្រើប្រាស់ដីធ្លីបានត្រឹមត្រូវ។ គោលនយោបាយនិងក្របខ័ណ្ឌច្បាប់នេះនឹងបន្តដោះស្រាយពីបញ្ហាវិវាទដីធ្លីដទៃទៀត ដែលនៅសេសសល់ លើកកំពស់ និងពន្លឿនការចុះបញ្ជីដីធ្លីទូទាំងប្រទេស រួមទាំងសហគមន៍ជនជាតិដើមភាគតិច ផ្តល់សម្បទានដីសង្គមកិច្ច និងដីសំរាប់ផលិតកម្មដល់ប្រជាជនដែលគ្មានដីធ្លី និងផ្តល់ការលើកទឹកចិត្តដល់ការអភិវឌ្ឍន៍លំនៅដ្ឋានដែលមានតម្លៃសមរម្យ។

19. រដ្ឋាភិបាល ជឿជាក់លើការគាំទ្រពីដៃគូពាក់ព័ន្ធទាំងអស់ ចូលរួមចំណែកដល់កិច្ចខិតខំរបស់រដ្ឋាភិបាល ដើម្បីធានាឱ្យសង្គមមួយមានសុខដុមរម្យនា និងសន្តិភាព ដោយមានការគោរពយ៉ាងពេញលេញដល់នីតិរដ្ឋ ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ សិទ្ធិមនុស្សទាំងអស់ រួមទាំងសិទ្ធិអភិវឌ្ឍន៍គឺជាសិទ្ធិមិនអាចបែងចែកបាន ហើយបញ្ហាសិទ្ធិមនុស្សត្រូវបានយកមកដោះស្រាយក្នុងបរិបទពិភពលោកតាមលក្ខណៈស្ថាបនា មិនប្រឈមមុខដាក់គ្នា មិនធ្វើនយោបាយ និងតាមរយៈកិច្ចសន្ទនាគ្នា។ ការគោរពអធិបតេយ្យភាពជាតិ និងបូរណភាពដែនដី ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋ ភាពមិនលំអៀង និងភាពមិនជ្រើសរើស ត្រូវកំណត់ថាជាគោលការណ៍ណែនាំសម្រាប់ការលើកកំពស់សិទ្ធិមនុស្ស ដោយត្រូវយកចិត្តទុកដាក់ដល់បរិបទសង្គម នយោបាយ និងប្រវត្តិសាស្ត្រនៃប្រទេសនីមួយៗ។

## ខ. កិច្ចសន្ទនាគ្នាទៅវិញទៅមក និងការឆ្លើយតបដោយរដ្ឋដែលស្ថិតក្រោមការពិនិត្យឡើងវិញ

20. ក្នុងអំឡុងកិច្ចសន្ទនាគ្នា គណៈប្រតិភូចំនួន៧៣ បានធ្វើសេចក្តីថ្លែងការណ៍។ អនុសាសន៍នានា ដែលបានធ្វើឡើងក្នុងអំឡុងកិច្ចសន្ទនានោះ នឹងមាននៅក្នុងផ្នែកទី២ នៃរបាយការណ៍នេះ។

21. ប្រទេសចិនបានកត់សំគាល់ថា កម្ពុជានៅតែរក្សាបានស្ថេរភាពនយោបាយនិងកំណើនសេដ្ឋកិច្ច បានធ្វើឱ្យប្រសើរដល់កំរិតរស់នៅរបស់ប្រជាជន និងបានខិតខំយ៉ាងធំធេងកាត់បន្ថយភាពក្រីក្រ លើកកំពស់កិច្ចធានាការពារសិទ្ធិមនុស្សតាមផ្លូវតុលាការ អភិវឌ្ឍន៍ការអប់រំ និងការថែទាំសុខភាព ព្រមទាំងកិច្ចធានាការពារសិទ្ធិក្រុមដែលងាយរងគ្រោះ។

22. ប្រទេសកូឡុំប៊ី បានគូសបញ្ជាក់ពីភាពរីកចំរើនដែលមាន ដើម្បីធានាពីសិទ្ធិរបស់ជនពិការនៅក្នុងច្បាប់របស់រដ្ឋ។

23. ប្រទេសកូស្តារីកា បានទទួលស្គាល់ពីការបង្កើតយន្តការជាតិប្រយុទ្ធប្រឆាំងទារុណកម្ម និងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិអំពីពិការភាព។ កូស្តារីកាបានទទូចឱ្យមានកិច្ចសហការបែបស្ថាបនាជាមួយអ្នកកាន់អាណត្តិនីតិវិធីពិសេស ទាំងមុនពេល កំឡុងពេល និងក្រោយពេលបេសសកម្មរបស់ពួកគេ។

24. ប្រទេសក្រូអាត បានទទួលស្គាល់ពីភាពរីកចំរើនក្នុងវិស័យអប់រំ។ ក្រូអាតបានសំដែងពីកង្វល់របស់ខ្លួនអំពីកុមារមកពីក្រុមជនជាតិដើមភាគតិច និងក្រុមជាតិពន្ធភាគតិចដែលនៅតែបន្តមិនទាន់បានទទួលប្រយោជន៍ពីវិស័យនេះ ស្ថានភាពនៃសេរីភាពជាមូលដ្ឋាន និងសិទ្ធិចូលរួមក្នុងជីវភាពនយោបាយ និងសាធារណៈ។

25. ប្រទេសគុយបាបានកោតសរសើរពីការអនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ផែនការជាតិកាត់បន្ថយពលកម្មកុមារ និងវិធានការដទៃទៀតដែលបានដាក់ចេញ ដើម្បីការពារកុមារ។

26. ប្រទេសឆែក បានកោតសរសើរពីលទ្ធផលសម្រេចបានក្នុងការកាត់បន្ថយភាពក្រីក្រ។ នៅមានកិច្ចការសេសសល់ជាច្រើនទៀតដែលត្រូវធ្វើក្នុងការអនុវត្តន៍អនុសាសន៍។ ឆែកសង្ឃឹមថាការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តនាពេលខាងមុខ អំពីការអនុវត្តន៍គោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាព នឹងផ្តល់ការជំរុញដែលចាំបាច់ដល់កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត។

27. សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ បានធ្វើការកត់សំគាល់ដោយការពេញចិត្តនូវការរីកចំរើនគួរឱ្យកត់សំគាល់ នៅក្នុងវិស័យនៃការកាត់បន្ថយភាពក្រីក្រ ការអប់រំ និងសុខភាពសាធារណៈ និងក្នុងការប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ និងការជួញដូរមនុស្ស។

28. ប្រទេសដាណឺម៉ាក នៅតែមានការបារម្ភយ៉ាងជ្រាលជ្រៅអំពីស្ថានភាពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមទាំងការរំលាយគណៈបក្សប្រឆាំងដ៏ចំបងផង។ ដាណឺម៉ាកបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការអប់រំក្មេងស្រី និងស្ត្រី ដែលនឹងនាំពួកគេទៅរកការរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍន៍សង្គម។

29.ប្រទេសអេហ្ស៊ីបបានកោតសរសើរពីកិច្ចខិតខំប្រឹងប្រែងពង្រឹងសិទ្ធិមនុស្សនិងការទទួលយករបស់រដ្ឋនូវសំណើរបង្កើតស្ថាប័នជាតិសិទ្ធិមនុស្សមួយដែលឯករាជ្យ។ កម្ពុជាក៏បានខិតខំប្រឹងប្រែងពង្រឹងសិទ្ធិជនពិការតាមរយៈផែនការយុទ្ធសាស្ត្រជាតិរបស់ខ្លួនសំរាប់ឆ្នាំ២០១៤-២០១៨។

30. ប្រទេសហ្វីជី បានអបអរសាទររដ្ឋនេះពីការកើនឡើងជាទៀងទាត់នៅក្នុងថវិការជាតិរបស់ខ្លួនដែលបានលៃបំរុងសំរាប់ចំណាយនានាពាក់ព័ន្ធនឹងអាកាសធាតុ ព្រមទាំងផែនការយុទ្ធសាស្ត្រជាតិរបស់ខ្លួនអំពីការគ្រប់គ្រងគ្រោះមហន្តរាយសំរាប់សុខាភិបាល និងផែនការយុទ្ធសាស្ត្រសម្រាប់ការប្រែប្រួលអាកាសធាតុ។

31. ប្រទេសហ្វាំងឡង់ ព្រួយបារម្ភពីការរួមតូចលំហពលរដ្ឋ និងប្រជាធិបតេយ្យ ជាពិសេសការដាក់កំហិតលើសេរីភាពសមាគម ការជួបប្រជុំ និងការសម្តែងមតិតាមរយៈច្បាប់និងបទប្បញ្ញត្តិដែលមានលក្ខណៈគាបសង្កត់។

32. ប្រទេសបារាំង បានស្វាគមន៍ដល់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ និងកែលំអប្រព័ន្ធសុខាភិបាល និងកិច្ចការពារសង្គម។ បារាំងបានកត់សំគាល់ពីវិធានការវិជ្ជមាននានាដែលរដ្ឋាភិបាលបានដាក់ចេញ ដើម្បីបើកចំហឡើងវិញនូវលំហនយោបាយ និងបានលើកទឹកចិត្តដល់រដ្ឋឱ្យអនុវត្តន៍តាមវិធានការទាំងនោះ។

33. ប្រទេសហ្សកហ្ស៊ី បានកត់សំគាល់ពីច្បាប់ពង្រឹងឯករាជ្យភាពប្រព័ន្ធតុលាការ និងបានលើកទឹកចិត្តឱ្យរដ្ឋបន្តដំណើរការកំណែទម្រង់នៅក្នុងទិសដៅមួយនេះ។ ហ្សកហ្ស៊ីក៏បានស្វាគមន៍ដល់ការបង្កើតយន្តការប្រឆាំងទារុណកម្មឯករាជ្យថ្នាក់ជាតិមួយ ស្របតាមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តិ ឬទណ្ឌកម្មដទៃទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក។

34. ប្រទេសអាឡឺម៉ង់ បានកោតសរសើរពីការកែលំអក្នុងកិច្ចការពារសិទ្ធិកុមារ និងកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។

35. ប្រទេសក្រិក បានកត់សំគាល់ពីភាពរីកចំរើនពីការធ្វើបរិយាប័ន្នស្រីស្រលាញ់ស្រី ប្រុសស្រលាញ់ប្រុស អ្នកស្រលាញ់ទាំងពីរភេទ អ្នកកែភេទ អ្នកមានភេទមិនច្បាស់ និងអ្នកដែលមិនប្រាកដពីភេទខ្លួន និងការបង្កើតសំណាញ់សុវត្ថិភាពសំរាប់ក្រុមដែលងាយរងគ្រោះបំផុត រួមទាំងជនពិការផង។ ក្រិកបានសំដែងការព្រួយបារម្ភយ៉ាងជ្រាលជ្រៅអំពីការកាន់តែអាក្រក់ទៅនៃស្ថានភាពសិទ្ធិមនុស្សជាទូទៅនៅក្នុងប្រទេស។

36. ប្រទេសហុងឌុយរ៉ាស់ បានអបអរសាទររដ្ឋពីលទ្ធផលដែលទទួលបានក្នុងការអនុវត្តន៍អនុសាសន៍ UPR ពីជុំមុនៗ និងការផ្តល់សច្ចាប័នរបស់ខ្លួនចំពោះសន្ធិសញ្ញាសិទ្ធិមនុស្សចំនួន៨។ ហុងឌុយរ៉ាស់បានកោតសរសើររដ្ឋចំពោះការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តរបស់ខ្លួនដែលបានធ្វើ។

37. ប្រទេសអ៊ីស្លង់ បានស្វាគមន៍ចំពោះវិធានការវិជ្ជមាននានា ដែលរដ្ឋាភិបាលបានដាក់ចេញ ដើម្បីលើកស្ទួយសិទ្ធិមនុស្ស និងការគាំទ្រយ៉ាងជាប់លាប់ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

38. ប្រទេសឥណ្ឌាបានកោតសរសើរកម្ពុជា ចំពោះការកាត់បន្ថយអាត្រាភាពក្រីក្រ និងការក្លាយខ្លួនជាប្រទេសដែលមានចំណូលមធ្យមទាប។ ឥណ្ឌាក៏បានកោតសរសើរពីភាពរីកចំរើននៅក្នុងការអប់រំកំរិតបឋមសិក្សា និងមធ្យមសិក្សា និងក្នុងការធានាពីអាត្រាកំរិតខ្ពស់នៃការចុះឈ្មោះចូលរៀនរបស់សិស្សនារីនៅក្នុងការអប់រំកំរិតខ្ពស់ ព្រមទាំងការលើកកំពស់និងការការពារសិទ្ធិជនពិការ។

39. ប្រទេសឥណ្ឌូនេស៊ី បានស្វាគមន៍ពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម ក្នុងឆ្នាំ២០១៧។ ឥណ្ឌូនេស៊ីក៏បានកោតសរសើរពីការអនុម័តផែនការយុទ្ធសាស្ត្រជាតិអំពីពិការភាពសំរាប់ឆ្នាំ២០១៤-២០១៨ និងការអនុវត្តន៍ផែនការជាតិអំពីការបញ្ជ្រាបយេនឌ័រទៅក្នុង២៩ ក្រសួង-ស្ថាប័ន ដើម្បីលើកកំពស់សមភាពយេនឌ័រនៅក្នុងសេវាសាធារណៈ។

40. សាធារណៈរដ្ឋអ៊ីស្លាមអ៊ីរ៉ង់បានកោតសរសើរដល់រដ្ឋពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋនោះ ដើម្បីលើកកំពស់ការអប់រំសិទ្ធិមនុស្ស និងការបណ្តុះបណ្តាលមន្ត្រីប្រតិបត្តិច្បាប់និងមន្ត្រីរាជការ។ អ៊ីរ៉ង់ ក៏បានស្វាគមន៍ដល់កិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម។

41. ប្រទេសអ៊ីរ៉ាក់ បានស្វាគមន៍ដល់ការបណ្តុះបណ្តាលសិទ្ធិមនុស្សដែលបានផ្តល់ឱ្យមន្ត្រីប្រតិបត្តិច្បាប់និងចៅក្រម។ អ៊ីរ៉ាក់ក៏បានស្វាគមន៍ដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋ កាត់បន្ថយភាពក្រីក្រ។

42. ប្រទេសអៀឡង់ដ៍បានទទួលស្គាល់ពីកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យមានវឌ្ឍនភាពសិទ្ធិមនុស្សនៅក្នុងស្រុក និងបានកោតសរសើរពីការរីកចំរើនដែលទទួលបានតាំងពីជុំមុននៃUPR រួមទាំងការងារក្នុងការបង្ការការជួញដូរមនុស្ស។

43. ប្រទេសអ៊ីតាលីបានផ្តល់អនុសាសន៍។

44. ប្រទេសជប៉ុនបានស្វាគមន៍ពីការបន្តអនុស្សារណៈនៃការយោគយល់ជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងបានរំពឹងទុកពីការការចាត់វិធានការជាក់ស្តែងអំពីជំហានបន្ថែមទៀតដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យនិងលំហានយោបាយ។ ជប៉ុនសង្ឃឹមថា កម្ពុជានឹងពង្រឹងការត្រួតពិនិត្យលើអង្គភាពនានាដែលពាក់ព័ន្ធនឹងការបញ្ជូនពលករទៅក្រៅប្រទេស។

45. សាធារណៈរដ្ឋប្រជាធិតេយ្យប្រជាមានិតឡាវបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងលប់បំបាត់ការរើសអើងប្រឆាំងនារីភេទ និងលើកកំពស់សមភាពយេនឌ័រ។ ឡាវក៏បានស្វាគមន៍ចំពោះភាពរីកចំរើននៅក្នុងវិស័យអប់រំ។

46. ប្រទេសឡាតវី បានកត់សំគាល់ពីដំណើរទស្សនកិច្ចរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងថា កម្ពុជាបានទទួលយកដំណើរទស្សនកិច្ចដែលដាក់ស្នើសុំដោយអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជនពិការនិងអ្នកជំនាញការឯករាជ្យស្តីពីការការពារប្រឆាំងនឹងអំពើហិង្សា និងការរើសអើង ដោយសារទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ។

47. ប្រទេសលីទុយអានី បានទទួលស្គាល់ពីកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យប្រសើរដល់ស្ថានភាពសិទ្ធិមនុស្ស និងបានទទូចឱ្យកម្ពុជាចងក្រងរួមគ្នា នូវវិធានការរបស់ខ្លួនក្នុងការដោះស្រាយបញ្ហាប្រឈមសិទ្ធិមនុស្សធ្ងន់ធ្ងរដែលនៅតែបន្តមាន។

48. ប្រទេសម៉ាឡេស៊ី មានក្តីសោមនស្សចំពោះកិច្ចខិតខំប្រឹងប្រែងលើកកំពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ម៉ាឡេស៊ី ក៏បានកត់សំគាល់ពីការរីកចំរើនក្នុងការធ្វើឱ្យកាន់តែប្រសើរដល់សេវាថៃទាំសុខភាព ដោយគូសបញ្ជាក់ថា ក្រោមផែនការយុទ្ធសាស្ត្រសុខាភិបាលសំរាប់ឆ្នាំ២០១៦-២០២០ បុគ្គលគ្រប់រូបរួមទាំងអ្នកទាំងឡាយដែលរស់នៅតំបន់ជនបទ អាចទទួលបានសេវាថៃទាំសុខភាពដោយស្មើភាពគ្នា។

49. ប្រទេសម៉ាលឌីវ បានទទួលស្គាល់ពីការអនុម័តផែនការយុទ្ធសាស្ត្រសុខាភិបាលសំរាប់ឆ្នាំ២០១៦-២០២០ និងក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីកិច្ចការពារសង្គមសំរាប់ឆ្នាំ២០១៦-២០២៥ និងយន្តការប្រឆាំងទារុណកម្មថ្នាក់ជាតិ។

50. ប្រទេសម៉ិចស៊ិកូបានកោតសរសើរចំពោះការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម និងនាយកដ្ឋានការពារស្ត្រីតាមផ្លូវច្បាប់នៅក្រសួងកិច្ចការនារី។

51. ប្រទេសម៉ុងតេណាក្រូបានស្វាគមន៍ដល់កិច្ចខិតខំប្រឹងប្រែងពង្រឹងកិច្ចការពារសិទ្ធិកុមារជាពិសេស ក្មេងតាមចិញ្ចើមថ្នល់និងក្មេងកំព្រា។ ម៉ុងតេណេក្រូបានទទូចឱ្យរដ្ឋាភិបាលស៊ើបអង្កេតគ្រប់ករណីនៃការធ្វើអាជីវកម្មផ្លូវភេទកុមារ និងផ្តន្ទាទោសជនល្មើស។

52. ប្រទេសមីយ៉ានម៉ា បានកោតសរសើរដល់ការអនុវត្តន៍ដោយជោគជ័យ នៃអនុសាសន៍នានា និងត្រូវបានលើកទឹកចិត្តដោយការអភិវឌ្ឍន៍យ៉ាងធំធេងក្នុងការកាត់បន្ថយភាពក្រីក្រ ការលើកកំពស់សមធម៌ និងសមភាពយេនឌ័រ ព្រមទាំងការអប់រំ និងការថៃទាំសុខភាព។

53. ប្រទេសនេប៉ាល់ បានកោតសរសើរពីការកាត់បន្ថយភាពក្រីក្រ និងការកែលំអកំរិតរស់នៅ ដែលនឹងមានផលប៉ះពាល់ជាសក្តានុពលដល់ការទទួលបានសិទ្ធិមនុស្ស។

54. ប្រទេសហូឡង់ដ៏ បានកោតសរសើរពីការប្តេជ្ញាចិត្តចំពោះសេចក្តីណែនាំបែបបរិយាប័ន្ន អំពីបញ្ហាទំនោរផ្លូវភេទនិងការអប់រំផ្លូវភេទ។ ហូឡង់ដ៏នៅតែមានកង្វល់អំពីការកើនឡើងពីការដាក់កំហិតលើសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ។

55. ប្រទេសណូវែលហ្សេឡង់ដ៏ បានកោតសរសើរដល់ការដោះលែងអ្នកទោសនយោបាយមួយចំនួនកាលពីខែកញ្ញា ឆ្នាំ២០១៨។ ណូវែលហ្សេឡង់ដ៏នៅតែបន្តកង្វល់ពីស្ថានភាពនយោបាយ។

56. ប្រទេសណ័រវេស បានស្វាគមន៍ការចូលរួមរបស់រដ្ឋក្នុងដំណើរការ UPR តែនៅតែរក្សាពីកង្វល់របស់ខ្លួនអំពីការវិវត្តន៍ប្រជាធិបតេយ្យ រួមទាំងការបោះឆ្នោតកាលពីពេលថ្មីៗនេះ។

57. ប្រទេសប៉ាគីស្ថាន បានកត់សំគាល់ដោយការពេញចិត្តពីកិច្ចខិតខំប្រឹងប្រែងគួរឱ្យកត់សំគាល់ ដើម្បីលប់បំបាត់ការរើសអើងប្រឆាំងនារីភេទ និងដើម្បីលើកកំពស់សមធម៌ និងសមភាពយេនឌ័រ តាមរយៈការបង្កើត និងការអនុវត្តន៍ច្បាប់ គោលនយោបាយ ផែនការសកម្មភាព និងកម្មវិធីផ្សេងៗ។

58. ប្រទេសហ្វីលីពីនបានទទួលស្គាល់ផែនការរបស់រដ្ឋាភិបាលដើម្បីសម្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាព ទៅជាបរិបទក្នុងស្រុក និងបានកោតសរសើរពីកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកំពស់ការយល់ដឹងសិទ្ធិមនុស្ស តាមរយៈការអប់រំ និងការបណ្តុះបណ្តាល។

59. ប្រទេសព័រទុយហ្គាល់ បានស្វាគមន៍ពីវិធានការនានាដែលបានដាក់ចេញដើម្បីបំពេញសិទ្ធិទទួលបានសុខភាព។

60. សាធារណៈរដ្ឋកូរ៉េ ត្រូវបានលើកទឹកចិត្តដោយសកម្មភាព និងវិធានការដែលបានដាក់ចេញដើម្បីការពារសិទ្ធិស្ត្រី និងកុមារ កម្មករ និងជនពិការ និងបានកោតសរសើរដល់រដ្ឋចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើឱ្យបានសម្រេចនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាព។

61. សាធារណៈរដ្ឋម៉ុលដូវ៉ា បានស្វាគមន៍ចំពោះវិធានការនានាដែលបានដាក់ចេញ ដើម្បីបង្ការអំពើហិង្សាយេនឌ័រប្រឆាំងនារីភេទ និងការកែលំអសិទ្ធិទទួលបានប្រព័ន្ធយុត្តិធម៌របស់ស្ត្រី។

62. សហព័ន្ធរុស្ស៊ី បានស្វាគមន៍ដល់កិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រហួសហេតុ ផ្តល់ការអភិវឌ្ឍន៍ប្រកបដោយចេរភាព និងកែលំអការទទួលបានការអប់រំ និងសុខភាព។ រុស្ស៊ី បានកត់សំគាល់ពីវិធានការនានាដែលរដ្ឋាភិបាលបានដាក់ចេញ ដើម្បីការពារស្ត្រី និងកុមារពីអំពើហិង្សាក្នុងគ្រួសារ។

63. ប្រទេសសេណេហ្គាល បានស្វាគមន៍កិច្ចខិតខំប្រឹងប្រែងពង្រឹងនីតិរដ្ឋ ជាពិសេសតាមរយៈការផ្តល់ឯករាជ្យភាពដល់ប្រព័ន្ធយុត្តិធម៌ ដូចដែលបានបញ្ជាក់យ៉ាងច្បាស់តាមរយៈសវនាការដ៏យុត្តិធម៌ និងមានសណ្តាប់ធ្នាប់ ដោយការប្រកាន់យ៉ាងខ្ជាប់នូវសិទ្ធិនានារបស់ភាគី។

64. ប្រទេសសែប៊ី បានកោតសរសើរពីកិច្ចខិតខំប្រឹងប្រែងកែលំអស្ថានភាពសិទ្ធិមនុស្សរបស់ស្ត្រី និងកុមារ។

65. ប្រទេសសឹង្ហបុរី បានកោតសរសើរកម្ពុជាចំពោះការបានកាត់បន្ថយអាត្រាភាពក្រីក្រគួរឱ្យកត់សំគាល់ និងការបានកែលំអសិទ្ធិទទួលបានសេវាថែទាំសុខភាព ដូចបានឃើញនៅក្នុងការធ្លាក់ចុះគួរឱ្យកត់សំគាល់នៃអាត្រាមរណៈកុមារ និងប្រេវ៉ាឡង់HIV នៅក្នុងប្រជាជនពេញវ័យ។

66. ប្រទេសស្លូវ៉ានី បានស្វាគមន៍វិធានការនានាដែលរដ្ឋាភិបាលបានដាក់ចេញ ដើម្បីលប់បំបាត់ការរើសអើងប្រឆាំងនារីភេទ និងលើកកំពស់សមភាពយេនឌ័រ។ ស្លូវ៉ានី បានលើកទឹកចិត្តរដ្ឋាភិបាលឱ្យផ្តន្ទាទោសជនល្មើសពីអំពើហិង្សាបែបនេះ។ ទោះជាយ៉ាងណាក៏ដោយ ស្លូវ៉ានី នៅតែបារម្ភពីការឃាយី និងការបំភិតបំភ័យដល់អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងកម្មករសហជីព។

67. ប្រទេសអេស្ប៉ាញ មានការបារម្ភពីស្ថានភាពអ្នកគ្មានសញ្ជាតិនៅកម្ពុជា។

68. ប្រទេសស៊ុយអែតបានទទួលស្គាល់វិធានការនានាដែលបានដាក់ចេញដោយកម្ពុជា ដើម្បីពង្រឹងការទទួលបានពេញលេញនូវសិទ្ធិមនុស្សដោយស្រីស្រលាញ់ស្រីដូចគ្នា ប្រុសស្រលាញ់ប្រុស អ្នកកែភេទ និងអ្នកដែលមានភេទមិនច្បាស់លាស់។ ស៊ុយអែតមានការបារម្ភពីការវិវត្តន៍ជាអវិជ្ជមានពីសិទ្ធិនយោបាយ និងការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ដើម្បីដាក់កំហិតសិទ្ធិមនុស្ស រួមចំណែកដល់ការភ័យខ្លាច ការបំភិតបំភ័យ និងស្វ័យតិះទៀន។

69.ប្រទេសស្វីសមានការព្រួយបារម្ភយ៉ាងជ្រាលជ្រៅពីការខូចខាតកាន់តែធ្ងន់ធ្ងរទៅនៃសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ រួមទាំងការដាក់កំហិតលើសេរីភាពនៃការសំដែងមតិ និងសង្គមស៊ីវិល និងការរំលាយគណៈបក្សប្រឆាំងដ៏ចំបងនៅមុនការបោះឆ្នោតឆ្នាំ២០១៨។

70. ប្រទេសថៃឡង់ដ៍ បានកោតសរសើរពីកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ក្នុងគ្រប់វិសាលភាព ដែលបានលើកឋានៈសេដ្ឋកិច្ចរបស់កម្ពុជា ទៅកាន់ឋានៈនៃប្រទេសដែលមានចំណូលមធ្យមកំរិតទាបនៅឆ្នាំ២០១៥។

71. ប្រទេសតូហ្គូ បានស្វាគមន៍ពីការរីកចំរើនគួរឱ្យកត់សំគាល់ ក្នុងការអនុវត្តន៍អនុសាសន៍ ដែលបានដាក់ជូនកាលពីការត្រួតពិនិត្យជុំមុន។ តូហ្គូបានកត់សំគាល់ដោយការពេញចិត្តពីការកែលំអនៅក្នុងសិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គម ជាពិសេសសិទ្ធិសុខភាព ទៅការការពារសង្គម និងការកើនឡើងប្រាក់ឈ្នួលអប្បបរមា។

72. ប្រទេសទុយនេស៊ី បានស្វាគមន៍ច្បាប់ដែលត្រូវបានអនុម័តតាំងពីការត្រួតពិនិត្យជុំមុន ក្នុងការគាំទ្រដល់ក្របខ័ណ្ឌស្ថាប័ន និងច្បាប់សិទ្ធិមនុស្ស ជាពិសេសយន្តការជាតិប្រឆាំងទារុណកម្ម និងការការពារជនពិការ កុមារក្នុងស្ថានភាពលំបាក និងកុមារគ្មានទីពឹង។

73. ប្រទេសតួគី បានកោតសរសើរដល់ការចូលរួមរបស់រដ្ឋជាមួយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងការខិតទៅជិតសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាព។ តួគី បានស្វាគមន៍សេរីភាពដែលអង្គការមិនមែនរដ្ឋាភិបាលក្រោមច្បាប់កម្ពុជាទទួលបាន ការបង្កើតឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ និងច្បាប់វិសោធនកម្មគណៈបក្សនយោបាយ។

74. ប្រទេសអ៊ុយក្រែន បានទទួលស្គាល់ពីការផ្តល់សច្ចាប័នលើលិខិតូបករណ៍សិទ្ធិមនុស្សសំខាន់ៗ។ អ៊ុយក្រែនមានការបារម្ភពីការធ្វើឱ្យខូចខាតដល់ប្រព័ន្ធយុត្តិធម៌ និងច្បាប់ដែលដាក់កំហិតដល់សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ អ៊ុយក្រែនបានលើកទឹកចិត្តឱ្យរដ្ឋ ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនីតិវិធីពិសេស និងបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិដ៏មានប្រសិទ្ធភាពមួយ។

75. សហរាជាណាចក្រនៃចក្រភពអង់គ្លេស និងអៀកឡង់ដ៏ខាងជើង មានការបារម្ភពីការស្រុតចុះនៃលំហប្រជាធិបតេយ្យដូចបានឃើញនៅក្នុងការរំលាយគណៈបក្សសង្គ្រោះជាតិ ការដាក់ពន្ធនាគារលោកកឹម សុខា និងការបោះឆ្នោតជាតិកាលពីខែកក្កដា ឆ្នាំ២០១៨ ដែលខ្វះធម្មានុរូប។

76. សហរដ្ឋអាមេរិច នៅតែរក្សាក្តីកង្វល់យ៉ាងខ្លាំងអំពីការបង្ក្រាបគណៈបក្សប្រឆាំង ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសង្គមស៊ីវិល ព្រមទាំងការដាក់កំហិតមិនត្រឹមត្រូវដល់កម្មករពីសិទ្ធិមានសេរីភាពខាងសមាគម និងការជួបប្រជុំដោយសន្តិវិធី ដែលជាលទ្ធផលដល់ការបោះឆ្នោតកាលពីខែកក្កដា ឆ្នាំ២០១៨ ដែលមិនសេរី និងមិនត្រឹមត្រូវយ៉ាងពិតប្រាកដ។

77. ប្រទេសអ៊ុយរុយហ្គាយ បានកោតសរសើរដល់វិធានការនានាដែលបានដាក់ចេញដើម្បីលប់បំបាត់ពលកម្មកុមារ និងអំពើហិង្សាប្រឆាំងស្ត្រីនិងកុមារី។ អ៊ុយរុយហ្គាយ បានទទូចឱ្យរដ្ឋបន្តសកម្មភាពបង្ការអំពើហិង្សា និងការបៀតបៀនផ្លូវភេទ រួមទាំងបទរំលោភសេពសន្ថវៈ និងលើកស្ទួយយន្តការបណ្តឹងឱ្យមានប្រសិទ្ធភាព ព្រមទាំងការថែទាំផ្លូវកាយ និងចិត្តសាស្ត្រដល់ជនរងគ្រោះ។

78. សាធារណៈរដ្ឋបូលីវ៉ារៀននៃវេណេហ្ស៊ុយអេឡាបានកត់សំគាល់ពីកំណើនសេដ្ឋកិច្ចថេរ និងការកាត់បន្ថយភាពក្រីក្រ។ វេណេហ្ស៊ុយអេឡា បានកត់សំគាល់ផងដែរពីផែនការយុទ្ធសាស្ត្រសុខាភិបាលសំរាប់ឆ្នាំ២០១៦-២០២០ ច្បាប់ស្តីពីការលប់បំបាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ការអប់រំកំរិតបឋមសិក្សាជាសកល និងភាពរីកចំរើនក្នុងការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ស្របតាមគោលការណ៍ទីក្រុងប៉ារីស។

79. គណៈប្រតិភូកម្ពុជាបានគូសបញ្ជាក់ថា គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាគឺជាស្ថាប័នកណ្តាលដែលត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលជាមួយក្រសួង និងអ្នកពាក់ព័ន្ធដទៃទៀត នៅពេលរៀបចំចងក្រងរបាយការណ៍សំរាប់ស្ថាប័នសន្ធិសញ្ញា និងតាមឃ្លាំមើលការអនុវត្តន៍អនុសាសន៍នានាដែលបានដាក់ជូនដោយស្ថាប័នសន្ធិសញ្ញាទាំងនោះនិងនីតិវិធីពិសេស។ រដ្ឋាភិបាលបានចេញអនុក្រិត្យមួយកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ បង្កើតក្រុមការងារអន្តរក្រសួង ដែលមានសមាសភាពមកពីគ្រប់ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីធ្វើឱ្យការសម្របសម្រួលកាន់តែប្រសើរ នៅពេលណារៀបចំរបាយការណ៍។

80. ក្រសួងព័ត៌មានបានដឹកនាំនិងសហការជាមួយស្ថានទូតស៊ុយអែត និងអង្គការយូណេស្កូ អំពីការធ្វើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន។ ដំណើរការធ្វើសេចក្តីព្រាងច្បាប់នេះអនុវត្តន៍តាមរយៈការបង្កើតក្រុមការងាររួមមួយដែលមានសមាសភាពមកពីស្ថាប័នរដ្ឋ ទីភ្នាក់ងារសហប្រជាជាតិ អង្គការសង្គមស៊ីវិល អ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយដែលមានវិជ្ជាជីវៈ អ្នកសិក្សា អ្នកស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍។ រដ្ឋាភិបាលមានការប្តេជ្ញាបង្ហើយសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន រួមជាមួយច្បាប់ដ៏សំខាន់ពីរទៀតគឺច្បាប់ប្រឆាំងឧក្រិដ្ឋកម្មព័ត៌មានវិទ្យា និងវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន។

81. រដ្ឋាភិបាលមានផែនការ លើកកំពស់សមភាពយេនឌ័រ និងការអប់រំពីបញ្ហាផ្លូវភេទដើម្បីលប់បំបាត់ការរើសអើង និងអំពើហិង្សាយេនឌ័រ រួមទាំងតាមរយៈការបញ្ជ្រាបសមភាពយេនឌ័រនៅក្នុងក្របខ័ណ្ឌគោលនយោបាយ និងផែនការអភិវឌ្ឍន៍ជាតិ ការកាត់បន្ថយគម្លាតយេនឌ័រក្នុងការអប់រំ ការលើកកំពស់ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងគំនិតផ្តួចផ្តើមសហគ្រិនភាពស្ត្រី ការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារនិងការបៀតបៀនផ្លូវភេទស្ត្រីនិងកុមារ ការលើកកំពស់សីលធម៌សង្គម សេចក្តីថ្លៃថ្នូររបស់ស្ត្រីនិងគ្រួសារកម្ពុជា ការកែលំអសេវាកម្មផ្លូវច្បាប់សំរាប់ស្ត្រីនិងកុមារ និងការអនុវត្តន៍ក្របខ័ណ្ឌគោលនយោបាយការពារសង្គមសំរាប់ឆ្នាំ២០១៦-២០២៥។

82. ទោះបីមិនមានក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ស្តីពីសិទ្ធិសំរាប់សហគមន៍ស្រីស្រលាញ់ស្រី ប្រុសស្រលាញ់ប្រុស អ្នកស្រលាញ់ទាំងពីរភេទនិងអ្នកកែភេទក៏ដោយ ក៏រដ្ឋាភិបាលបានចាត់វិធានការលប់បំបាត់ការរើសអើងប្រឆាំងនឹងសហគមន៍ពួកគេ តាមរយៈការរៀបចំយុទ្ធនាការលើកកំពស់ការយល់ដឹងជាសាធារណៈ ដោយធ្វើការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងក្នុងបរិបទនៃការអប់រំផ្លូវការ និងក្រៅផ្លូវការ។ ទោះបីជាក្រមរដ្ឋប្បវេណីនៅតែមិនទាន់ទទួលស្គាល់ធម្មានុរូបនៃការចុះបញ្ជី និងការរៀបអាពាហ៍ពិពាហ៍អ្នកស្រលាញ់ភេទដូចគ្នាក៏ដោយ ក៏ជាក់ស្តែង ក្រមមិនបានផ្តន្ទាទោសការអនុវត្តន៍ និងការរៀបអាពាហ៍ពិពាហ៍បែបនេះឡើយ។ តាមពិតអាពាហ៍ពិពាហ៍អ្នកស្រលាញ់ភេទដូចគ្នា បានក្លាយជារឿងធម្មតាទៅហើយនៅក្នុងសង្គមកម្ពុជាទាំងតាមការអនុវត្តន៍ជាប្រពៃណី និងវប្បធម៌។ ប្រហែល១០០០គូ នៃអ្នកស្រលាញ់ភេទដូចគ្នាបានរៀបការតាមប្រពៃណី ជាមួយនឹងពិធីជប់លៀងផងដែរ។

83. ការផ្សះផ្សាជាតិត្រូវតែជាការប្តេជ្ញាចិត្តមួយយ៉ាងពិតប្រាកដពីគ្រប់ភាគីពាក់ព័ន្ធ ដោយតំកល់ផលប្រយោជន៍ជាតិជាធំ ដោយគ្មានទទួលបញ្ជាពីអំណាចបរទេសណាមួយឡើយ។ ការចាត់វិធានការជាក់ស្តែងលើលោកកឹម សុខា និងស្ថាប័នដែលបានប្រព្រឹត្តិអំពើក្បត់ជាតិ និងការសមគំនិត គឺជាវិធីធម្មានុរូបតែមួយគត់ដើម្បីការពារសន្តិភាព និងប្រជាធិបតេយ្យក្រោមតំបូលនីតិរដ្ឋ។ អំពើក្បត់ជាតិ ចារកម្មឱ្យបរទេស និងការសមគំនិតជាមួយអំណាចបរទេសដែលបានតស៊ូមតិផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់ ត្រូវតែផ្តន្ទាទោសឱ្យបានធ្ងន់ធ្ងរតាមច្បាប់នៅគ្រប់ប្រទេស ហើយកម្ពុជាក៏គ្មានករណីលើកលែងនេះដែរ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋមានការសោកស្តាយថា វិធានការស្របច្បាប់តែមួយគត់ដែលរដ្ឋអធិបតេយ្យមួយអាចធ្វើបាន ត្រូវបានគេយកធ្វើនយោបាយក្រោមបដា"សិទ្ធិមនុស្សនិងប្រជាធិបតេយ្យ" ដោយសារមូលហេតុផលប្រយោជន៍នយោបាយភូមិសាស្រ្តរបស់រដ្ឋដទៃទៀត។

84. កម្ពុជា គឺជាឋានសួគ៌សំរាប់អង្គការមិនមែនរដ្ឋាភិបាល។ ជាមួយនឹងប្រជាជនសរុបប្រហែល១៥លាននាក់ គួរឱ្យមានការភ្ញាក់ផ្អើលដែលកម្ពុជាគឺជាលំនៅដ្ឋានសមាគមក្នុងស្រុកនិងអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលជាង៦០០០អង្គការបានចុះបញ្ជី និងមានជាង៤០០០សហជីព គឺជាតួរលេខមួយគួរឱ្យចាប់អារម្មណ៍គិតជាសមាមាត្រ បើប្រៀបធៀបជាមួយប្រទេសដទៃទៀតនៅក្នុងតំបន់។ ចាប់តាំងពីការដាក់ឱ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានសមាគមក្នុងស្រុកចំនួន៥០៩ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន៤០០បានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ គិតត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០១៨។ ចំនួនដ៏ច្រើនបែបនេះនៃអង្គការសង្គមស៊ីវិល គឺជាភស្តុតាងយ៉ាងច្បាស់ និងគួរឱ្យជឿជាក់បានពីការបើកចំហសំរាប់សង្គមស៊ីវិល។

ជាអកុសល មានអង្គការជាច្រើន នៅក្រោមហេតុផលថាមានសកម្មភាពដែលត្រូវសន្មត់ថាមនុស្ស ធម៌និងអភិវឌ្ឍន៍ ដែលផ្តល់មូលនីធិដោយស្ថាប័ន និងរដ្ឋាភិបាលបរទេស តាមពិតទៅបានចូលរួម យ៉ាងជ្រៅនៅក្នុងសកម្មភាពនយោបាយ។ កម្ពុជាមានការពេញចិត្តចំពោះការរួមវិភាគទានដោយ ស្មោះត្រង់ និងពិតប្រាកដពីអ្នកធ្វើការខាងសង្គម បរិដ្ឋាន និងសិទ្ធិមនុស្ស ដល់ការអភិវឌ្ឍន៍របស់ ប្រទេស។ ទោះជាយ៉ាងណាក៏ដោយ គ្មាននរណាម្នាក់នៅពីលើច្បាប់នោះទេ ហើយជនល្មើសត្រូវ ប្រឈមមុខនឹងការអនុវត្តន៍ច្បាប់ទាំងស្រុង រួមទាំងអ្នកទាំងឡាយណាដែលបានប្រើ និងបានធ្វើ អាជីវកម្មរបៀបវរៈសិទ្ធិសំរាប់គោលបំណងនយោបាយផង។

85. កម្ពុជាក៏បានយោងដល់ចំនុចវិជ្ជមានជាច្រើនលើកឡើងដោយអ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា នៅក្នុងសេចក្តីថ្លែងការណ៍បញ្ចប់បេសកកម្មរបស់លោកស្រី កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨។ លោកស្រីបានស្វាគមន៍ដល់ការបង្កើតក្រុមការងារមួយរបស់ រដ្ឋាភិបាលក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ កាលពីពេលថ្មីៗនេះ ដើម្បីពិគ្រោះយោបល់ជា មួយសង្គមស៊ីវិលឱ្យបានទៀងទាត់។ លោកស្រីក៏បានស្វាគមន៍ផងដែរចំពោះសារាចរណ៍ណែនាំ ថ្មីលេខ០៤០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ចេញដោយក្រសួងមហាផ្ទៃ ណែនាំដល់អាជ្ញាធរ ថ្នាក់ក្រោមជាតិកាលពីថ្ងៃ៣១ ខែតុលា ឆ្នាំ២០១៨ ឱ្យលប់ចោលលក្ខខណ្ឌតម្រូវពីការជូនដំណឹង ជាមុនឱ្យបាន៣ថ្ងៃ។

86. ក្នុងចំណោមលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិធំៗចំនួន៩ កម្ពុជាបានផ្តល់សច្ចាប័ន ចំនួន៨។ រដ្ឋាភិបាលក៏បានសិក្សាពីកត្តាផ្សេងៗដើម្បីកំណត់ពេលវេលា និងលក្ខខណ្ឌសមស្រប សំរាប់កម្ពុជាឱ្យចូលជាសមាជិក ឬផ្តល់សច្ចាប័នសន្ធិសញ្ញាអន្តរជាតិដទៃទៀត។

87. ប្រទេសវៀតណាមបានស្វាគមន៍ការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងដែលនៅតែបន្ត ដើម្បីការពារ និងលើកកំពស់សិទ្ធិមនុស្ស ជាពិសេស សិទ្ធិរបស់ក្រុមងាយរងគ្រោះ។ វៀតណាម បានកោតសរសើរពីសមិទ្ធផលរបស់រដ្ឋសម្រេចបានក្នុងឆ្នាំថ្មីៗនេះ រួមទាំងការកាត់បន្ថយភាពក្រី ក្រ សមភាពយេនឌ័រ ការអប់រំបឋមសិក្សាជាសកល និងការទទួលបានសេវាថែទាំសុខភាព។

88. ប្រទេសយេមែន បានស្វាគមន៍ការអនុម័តច្បាប់សិទ្ធិមនុស្សជាច្រើនដោយរដ្ឋាភិបាល រួមទាំងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ពិសេសស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ យេមែនក៏បានស្វាគមន៍ផងដែរពីសមិទ្ធផលដែល សម្រេចបាននៅក្នុងវិស័យសេវាសាធារណៈ ការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ។

89. ប្រទេសអាល់ហ្សេរី បានកត់សំគាល់ដោយការពេញចិត្តនូវការបង្កើតយន្តការជាតិបង្ការទារុណកម្ម និងការអនុម័តច្បាប់សំដៅការពារសិទ្ធិជនពិការ និងកុមារ ប្រឆាំងនឹងការប្រព្រឹត្តិលើដោយបន្ទាបបន្ថោក ពលកម្មដោយបង្ខំនិងអំពើហិង្សាផ្លូវភេទ។ អាល់ហ្សេរីបានលើកទឹកចិត្តកម្ពុជាឱ្យបន្តកំណែទម្រង់តុលាការរបស់ខ្លួន។

90. ប្រទេសអាហ្សង់ទីន បានកោតសរសើរកម្ពុជា ចំពោះការបានបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងទារុណកម្ម ថាជាយន្តការបង្ការថ្នាក់ជាតិរបស់ខ្លួន។

91. ប្រទេសអូស្ត្រាលី បានស្វាគមន៍ផែនការសកម្មភាពជាតិដើម្បីបង្ការអំពើហិង្សាប្រឆាំងស្ត្រីភេទ។ អូស្ត្រាលីនៅតែរក្សាកង្វល់អំពីលំហប្រជាធិបតេយ្យដែលនៅតែតានតឹង និងការរឹតត្បិតសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគម។

92. ប្រទេសអូទ្រីស បានទទួលស្គាល់ពីកិច្ចខិតខំប្រឹងប្រែងដោះស្រាយការទាមទារដែលលេចធ្លោក្នុងវិស័យដីធ្លី។ អូទ្រីសនៅតែបារម្ភយ៉ាងខ្លាំងអំពីស្ថានភាពកាន់តែធ្ងន់ធ្ងរទៅក្នុងវិស័យនីតិរដ្ឋ។ អូទ្រីសក៏មានកង្វល់ផងដែរអំពីអនាគតនៃប្រព័ន្ធតុលាការ។

93. ប្រទេសអាហ៊្សែបៃហ្សង់ បានស្វាគមន៍ពីភាពរីកចំរើននៅក្នុងវិស័យសុខាភិបាល រួមទាំងការអនុម័តផែនការយុទ្ធសាស្ត្រសុខាភិបាល សំរាប់ឆ្នាំ២០១៦-២០២០។ អាហ៊្សែបៃហ្សង់ក៏បានស្វាគមន៍ការពិតដែលថាភាពក្រីក្របានថយចុះ និងថាកិច្ចសហប្រតិបត្តិការត្រូវបានពង្រឹងជាមួយដៃគូសំរាប់ការអនុវត្តន៍ផែនការនានាសំដៅដល់ការអភិវឌ្ឍន៍ជនបទ និងកាត់បន្ថយភាពក្រីក្រ។

94. ប្រទេសប៊ែលហ្ស៊ិក បានស្វាគមន៍កិច្ចសហប្រតិបត្តិការរបស់រដ្ឋជាមួយអ្នករាយការណ៍ពិសេសអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ប៊ែលហ្ស៊ិក មានការបារម្ភពីការស្រុតចុះនៃលំហសង្គមស៊ីវិល និងការខ្វះឯករាជ្យភាពតុលាការ។

95. ប្រទេសបេណាំង បានស្វាគមន៍ពីកិច្ចខិតខំប្រឹងប្រែងលើកស្ទួយនិងការពារសិទ្ធិមនុស្សបន្ទាប់ពីការត្រួតពិនិត្យកាលពីជុំទី២របស់រដ្ឋ ជាពិសេសការផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិជាច្រើន។

96. ប្រទេសប៊ូតង់ បានកត់សំគាល់ដោយការពេញចិត្តនូវកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ជាពិសេសការអនុម័តច្បាប់អំពីតុលាការ និងការរៀបចំនិងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ប៊ូតង់ ក៏បានកត់សំគាល់ពីវិធានការនានា ដែលបានដាក់ចេញ ដើម្បីអប់រំ និងបណ្តុះបណ្តាលដល់មន្ត្រីរាជការ និងទីភ្នាក់ងារប្រតិបត្តិច្បាប់ អំពីសិទ្ធិមនុស្ស។

97. រដ្ឋពហុជាតិបូលីវី បានកោតសរសើរដល់ការសម្រេចចិត្តរបស់រដ្ឋដើម្បីលើកកំពស់សិទ្ធិមនុស្ស ដូចបានបង្ហាញតាមរយៈការផ្តល់សច្ចាប័នលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ ចំនួន៨ ក្នុងចំណោមលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិចំនួន៩។

98. ប្រទេសប្រេស៊ីលបានអំពាវនាវឱ្យកម្ពុជាបន្តស៊ើបអង្កេតគ្រប់ករណីនៃការរំលោភបំពានសិទ្ធិមនុស្សពីអតីតកាល និងការពារឯករាជ្យភាពពេញលេញនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ប្រេស៊ីលបានស្វាគមន៍ការផ្តល់សច្ចាប័នរបស់រដ្ឋលើសន្ធិសញ្ញាអន្តរជាតិ និងបានសម្តែងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋចំពោះភាពជឿនលឿននៃការការពារសង្គមរបស់កម្មករ។

99. ប្រទេសប្រ៊ុយណេ ដារូសាលឹម បានស្វាគមន៍ពីកិច្ចខិតខំប្រឹងប្រែងដល់សិទ្ធិជនពិការ រួមទាំងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព និងការរីកចំរើនលើផែនការជាតិប្រឆាំងពលកម្មកុមារ ដែលបានរួមបញ្ចូលការបណ្តុះបណ្តាលដល់គណៈកម្មាធិការជាតិពាក់ព័ន្ធ និងការកែទម្រង់យន្តការអធិការកិច្ច។

100. ប្រទេសកាណាដា នៅតែមានកង្វល់ពីការដាក់កំហិតលើសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងគណៈបក្សប្រឆាំង ហើយដែលកាន់តែធ្ងន់ធ្ងរទៀតគឺតាមរយៈការបោះឆ្នោតដែលមិនប្រជាធិបតេយ្យ រៀបចំឡើងក្នុងឆ្នាំ២០១៨។ កាណាដាតាមដានយ៉ាងយកចិត្តទុកដាក់ពីការអនុវត្តន៍កំណែទម្រង់ដែលបានប្រកាសកាលពីពេលថ្មីៗនេះដើម្បីពង្រីកលំហនយោបាយ។ កាណាដានឹងបន្តអំពាវនាវឱ្យរដ្ឋាភិបាល រៀបចំការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ និងស្តារឡើងវិញនូវសេរីភាពនៃការសម្តែងមតិ និងការចូលរួមនយោបាយ។

101. ប្រទេសឈីលី បានទទួលស្គាល់ពីកិច្ចខិតខំប្រឹងប្រែង លើកស្ទួយ និងការពារសិទ្ធិមនុស្ស ជាពិសេស ការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងទារុណកម្ម និងការប្រព្រឹត្តិអំពើឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក និងភាពរីកចំរើននៅក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌។

102. គណៈប្រតិភូកម្ពុជាបានគូសបញ្ជាក់ថា គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាបានសហការជាមួយអង្គការសង្គមស៊ីវិល ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ដែលត្រូវបានផ្តួចផ្តើមដោយក្រុមការងារសង្គមស៊ីវិល ហើយទើបពិភាក្សាជាមួយខាងគណៈកម្មាធិការ។ សេចក្តីព្រាងច្បាប់នេះ មិនទាន់បានបញ្ចប់នៅឡើយទេ។ គណៈកម្មាធិការនឹងបន្តធ្វើការជាមួយអ្នកពាក់ព័ន្ធ ជាពិសេស ជាមួយការិយាល័យ OHCHR នៅកម្ពុជា ដើម្បីធានាថា សេចក្តីព្រាងច្បាប់នេះ ស្របតាមគោលការណ៍ទីក្រុងប៉ារីស និងបទដ្ឋានអន្តរជាតិ។

103. គ្មានអ្នកកាសែតណាម្នាក់ត្រូវបានសំលាប់ដោយសារហេតុផលនយោបាយទេ តាំងពីឆ្នាំ២០០០មក។ រដ្ឋាភិបាលបានថ្កោលទោសរាល់ការវាយប្រហារលើសេរីភាពសារព័ត៌មាន នៅពេលណាមន្រ្តីសារព័ត៌មានបានធ្វើសកម្មភាពស្របតាមច្បាប់។ មិនមែនគ្រប់ឧបទ្ទវហេតុ សុទ្ធតែមានហេតុផលនយោបាយនោះទេ ជួនកាលអ្នកកាសែតមិនបានគោរពតាមវិធានសុវត្ថិភាព ឬខ្វះក្រមសីលធម៌នៅក្នុងសកម្មភាពរបស់ខ្លួន។ សេរីភាពសារព័ត៌មាន ត្រូវបានធានាការពារដោយរដ្ឋធម្មនុញ្ញ និងត្រូវបានប្បញ្ញត្តិដោយច្បាប់ស្តីពីសារព័ត៌មាន។ លើសពីនេះ នៅក្នុងកិច្ចខិតខំប្រឹងប្រែងលើកកំពស់សេរីភាពនៃការសម្តែងមតិ កម្ពុជាថែមទាំងបានដកទោសបញ្ញត្តិជាប់ពន្ធនាគារថាជាទោសទណ្ឌសំរាប់បទបរិហារកេរ្តិ៍ពីក្រមព្រហ្មទណ្ឌ និងបានផ្តល់កិច្ចធានាការពារថា គ្មានបុគ្គលណាម្នាក់ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសារតែការបញ្ចេញមតិរបស់ខ្លួនឡើយ។

104. ចំពោះដំណើរការបោះឆ្នោតឆ្នាំ២០១៨ និងការធ្វើវិសោធនកម្មច្បាប់គណៈបក្សនយោបាយនោះ ការធ្វើវិសោធនកម្មនេះត្រូវបានឈរលើគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ ច្បាប់វិសោធនកម្មនេះត្រូវបានអនុវត្តន៍ដោយមិនរើសអើងចំពោះគណៈបក្សនយោបាយទាំងអស់។ គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងច្បាប់វិសោធនកម្មនេះ បានគំរាមកំហែងដល់ប្រព័ន្ធពហុបក្សដូចមានកំណត់ដោយរដ្ឋធម្មនុញ្ញនោះទេ។ ដូចក្នុងគ្រប់ប្រទេសប្រជាធិបតេយ្យ ច្បាប់វិសោធនកម្មសំដៅដល់ការបង្ការអំពើបំពាន និងអំពើណាដែលមិនស្របនឹងគោលការណ៍ប្រជាធិបតេយ្យជាមូលដ្ឋាន ដូចជាការញុះញុងឱ្យមានការស្អប់ពូជសាសន៍ ការបរិហារកេរ្តិ៍ និងការបំផ្លាញស្រទាប់សង្គមរបស់ជាតិ។

105. តំណាងអចិន្ត្រៃយ៍ប្រចាំការិយាល័យអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ បានសង្កត់ធ្ងន់ថា ប្រតិភូមួយចំនួនបានផ្តល់អាទិភាពលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជាជាងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅពេលដោះស្រាយពីបញ្ហាកម្ពុជា។ ក្រុមសិទ្ធិជាមូលដ្ឋានទាំងពីរនេះ មិនគួរត្រូវបានយកចិត្តទុកដាក់ផ្សេងគ្នានោះទេ។ ការរីកលូតលាស់ផ្នែកសេដ្ឋកិច្ច បានបង្ហាញភស្តុតាងនៅកម្ពុជា ថាជាលទ្ធផលនៃសន្តិភាពដែលរកបានដោយលំបាក ក្រោមគោលនយោបាយរបស់នាយករដ្ឋមន្រ្តីដែលត្រូវបានគេប៉ាន់ស្មានមិនដល់ ខណៈដែលចំណុចឆកល្វែងមួយចំនួនដែលមិនសូវសំខាន់ត្រូវបានបំផ្លើស។ សំរាប់កម្ពុជា សន្តិភាពគឺជាបុរេលក្ខខណ្ឌដល់ការអភិវឌ្ឍន៍ ដែលរដ្ឋាភិបាលត្រូវតែការពារ ទោះក្នុងតម្លៃណាក៏ដោយ ដើម្បីលើកកំពស់សិទ្ធិ និងវិបុលភាពរបស់ប្រជាជន ជាពិសេសសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

106. កម្ពុជា មិនបានព្រងើយកន្តើយសិទ្ធិនិងសេរីភាពដទៃទៀតឡើយ។ កង្វល់នានាដែលបានលើកឡើងគួរត្រូវបានពិចារណា ដោយឈរលើមូលដ្ឋានគោរពគ្នាទៅវិញទៅមក។ ការត្រួតពិនិត្យជាសកលតាមកាលកំណត់ មិនមែនជាវេទិកាមួយសំរាប់ការឃោសនានយោបាយដែលផ្តល់ប្រយោជន៍ដល់ក្រុមមួយ ឬគណៈបក្សមួយ ដោយធ្វើឱ្យអ្នកដទៃខាតបង់ទេ។ សិទ្ធិមនុស្សមិនគួរត្រូវបានធ្វើនយោបាយទេ។ សិទ្ធិមនុស្សគួរត្រូវយកមកអនុវត្តន៍ដោយត្រឹមត្រូវ និងមិនលំអៀង។

107. កម្ពុជាបានងើបចេញពីសង្គ្រាម បន្ទាប់ពីបានទទួលរងការឈឺចាប់ដោយផ្ទាល់ពីឥទ្ធិពលដ៏វិនាសហិនហោចមក កម្ពុជាមានបំណងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងសន្តិភាពទូទាំងពិភពលោក ដោយសារតែគ្មានសន្តិភាព ក៏មិនអាចមានសិទ្ធិមនុស្សដែរ។ តាមពិតទៅ កម្ពុជាអាចក្លាយជាប្រទេសក្រោយសង្គ្រាមទីមួយនៅក្នុងប្រវត្តិសាស្ត្ររបស់អង្គការសហប្រជាជាតិ ចេញពីប្រទេសដែលទទួលកងកម្លាំងប្រតិបត្តិការរក្សាសន្តិភាពទៅជាប្រទេសបញ្ជូនកងកម្លាំងទៅរក្សាសន្តិភាព។

108. ទាក់ទងនឹងសិទ្ធិសេដ្ឋកិច្ច-សង្គម កម្ពុជាបានបង្ហាញនូវអំណរគុណសមិទ្ធផលគួរឱ្យកោតសរសើរដល់ការគាំទ្រដែលនៅតែបន្តមានពីសហគមន៍អន្តរជាតិ និងរដ្ឋដៃគូ។

109. កម្ពុជានៅតែរក្សាការប្តេជ្ញាចិត្ត ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូបែបស្ថាបនាជាមួយយន្តការសិទ្ធិមនុស្សសហប្រជាជាតិទាំងអស់ និងដៃគូពាក់ព័ន្ធ ដើម្បីរួមគ្នាឱ្យបានរឹងមាំថែមទៀតដល់ការលើកកំពស់ និងការការពារសិទ្ធិមនុស្សនៅក្នុងប្រទេស។

## III. សេចក្តីសន្និដ្ឋាន និង/ឬអនុសាសន៍

110. អនុសាសន៍នានាដូចខាងក្រោមនេះនឹងត្រូវយកទៅពិនិត្យពិចារណាដោយកម្ពុជា ដែលនឹងផ្តល់ចម្លើយក្នុងពេលវេលាសមស្រប ប៉ុន្តែមិនត្រូវឱ្យហួសសម័យប្រជុំលើកទី៤១ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស៖

110.1 *អនុលោមតាមកាតព្វកិច្ចក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក្នុងការបង្កើត ការអនុវត្តន៍ និងការកែសម្រួលគោលនយោបាយ និងបទប្បញ្ញត្តិ។* (អ៊ុយក្រែន)

110.2 *ពិចារណាពីការចូលជាសមាជិកនៃលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាមិនទាន់ក្លាយជារដ្ឋភាគី។ (ហុងឌុយរ៉ាស់)*

110.3 *បន្តស្វែងរកលទ្ធភាព ដើម្បីពង្រីកវិសាលភាពនៃការប្តេជ្ញាចិត្តជាអន្តរជាតិរបស់ខ្លួន តាមរយៈការផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដូចដែលបានផ្តល់អនុសាសន៍កាលពីពេលមុន។ (ឡាតវី)*

110.4 *ចូលជាសមាជិកនៃពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ (កូស្តារីកា)*

110.5 *ចូលជាសមាជិកនៃពិធីសារបន្ថែមទីពីរនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សំដៅដល់ការលុបបំបាត់ទោសប្រហារជីវិត។ (កូឡុំប៊ី)*

*ផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សំដៅដល់ការលុបបំបាត់ទោសប្រហារជីវិត។ (ប៊ែលហ្សិក), (ម៉ុងតេណេហ្គ្រូ), (អ៊ុយក្រែន)*

110.6 *ផ្តល់សច្ចាប័នលើពិធីសារបន្ថែមទីពីរនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សំដៅដល់ការលុបបំបាត់ទោសប្រហារជីវិត និងចាត់វិធានការផ្សេងៗដើម្បីលុបបំបាត់ទោសប្រហារជីវិត។ (ម៉ិចស៊ីកូ)*

110.7 ចូលជាសមាជិកនៃពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។(បេណាំង)

110.8 ពិចារណាពីការផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ។ (ហ្វីលីពីន)

110.9 ពិចារណាពីការផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ។ (អេហ្សីប)

110.10 ចូលជាសមាជិកនៃអនុសញ្ញាឆ្នាំ១៩៥៤ ពាក់ព័ន្ធនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និងអនុសញ្ញាឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ។ (បេណាំង)

110.11 ចេញលិខិតអញ្ជើញអចិន្ត្រៃយ៍មួយដល់នីតិវិធីពិសេសអង្គការសហប្រជាជាតិ និងសហប្រតិបត្តិការប្រកបដោយស្ថាបនាជាមួយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ព្រមទាំងជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា។ (អាល្លឺម៉ង់)[១]

110.12 ធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធ្វើវាឱ្យស្របទៅនឹងកាតព្វកិច្ចរបស់រដ្ឋ ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ (ក្រិក)

110.13 ទទួលយកសំណើសុំធ្វើទស្សនៈកិច្ចពីអ្នកកាន់អាណត្តិនីតិវិធីពិសេស។ (ហុងឌុយរ៉ាស់)

110.14 អនុវត្តឱ្យបានពេញលេញនូវអនុសាសន៍ទាំងឡាយ ដែលបានធ្វើនៅក្នុងរបាយការណ៍ចុងក្រោយរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា រួមទាំងរបាយការណ៍បន្ថែមរបស់គាត់ (A/HRC/39/73/Add.1)។ (ណូវែលហ្សេឡង់)

[១] នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

110.15 ចេញលិខិតអញ្ជើញអចិន្ត្រៃយ៍មួយដល់នីតិវិធីពិសេសទាំងអស់របស់អង្គការសហប្រជាជាតិ និងចូលរួមប្រកបដោយស្ថាបនាជាមួយការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងនីតិវិធីពិសេស។ (ក្រូអាត)[២]

110.16 ចេញលិខិតអញ្ជើញអចិន្ត្រៃយ៍មួយដល់គ្រប់នីតិវិធីពិសេស។ (អ៊ុយក្រែន)[៣]

110.17 ពង្រឹងកិច្ចសហការជាមួយនីតិវិធីពិសេស ចេញ និងអនុវត្តការអញ្ជើញអចិន្ត្រៃយ៍មួយដល់គ្រប់នីតិវិធីពិសេស ឱ្យបានមុនជុំបន្ទាប់នៃការពិនិត្យ UPR។ (ឆែក)[៤]

110.18 ពង្រឹងកិច្ចសហការជាមួយនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស តាមរយៈការឆ្លើយតបជាវិជ្ជមាន ចំពោះសំណើសុំទស្សនកិច្ចរបស់អ្នកកាន់អាណត្តិនីតិវិធីពិសេស ដែលមិនទាន់បានសម្រេចឱ្យ និងពិចារណាចេញលិខិតអញ្ជើញអចិន្ត្រៃយ៍មួយ ដល់អ្នកកាន់អាណត្តិនីតិវិធីពិសេសទាំងអស់ ដូចបានផ្តល់អនុសាសន៍កាលពីជុំមុនៗ។ (ឡាតវី)[៥]

110.19 ចូលរួមប្រកបដោយន័យស្ថាបនាជាមួយនីតិវិធីពិសេសទាំងអស់។ (អ៊ីតាលី)

110.20 បង្កើយកំណែទម្រង់ដីធ្លី ដើម្បីសម្រួលដល់ការទទួលបាន ការប្រើប្រាស់ និងការអភិវឌ្ឍន៍ដីសម្រាប់បុគ្គល និងសហគ្រាសខ្នាតតូច និងមធ្យម។ (សេណេហ្គាល់)

110.21 ចាត់វិធានការដើម្បីបង្កភាពងាយស្រួលក្នុងការបែងចែកដីសម្បទានសហគមន៍ដល់ជនជាតិដើមភាគតិច។ (តូហ្គូ)

[២]· នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។
[៣]· នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។
[៤]· នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។
[៥]· នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

110.22 អនុវត្តគោលនយោបាយតាំងទីលំនៅថ្មីឱ្យមានសង្គត់ភាព និងបង្កភាពងាយស្រួលដល់ដំណើរការផ្តល់កម្មសិទ្ធិដីសហគមន៍ដោយពិគ្រោះយោបល់ជាមួយសហគមន៍ សង្គមស៊ីវិល និងក្រុមជនជាតិដើមភាគតិច។ (សហរាជាណាចក្រនៃចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង)

110.23 ធានាថា រាល់ជម្លោះដីធ្លីដែលមិនទាន់បានដោះស្រាយ ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ត្រូវបានដោះស្រាយ តាមលក្ខណៈត្រឹមត្រូវ តម្លាភាព ចរចា និងផ្តល់សំណងសមរម្យ។ (អូទ្រីស)

110.24 ចាត់វិធានការចាំបាច់នានា ដើម្បីបង្កើតឡើងវិញនូវបរិយាកាសមួយ ដែលពោរពេញដោយការគោរពសិទ្ធិរបស់សង្គមស៊ីវិល ជាពិសេសតាមរយៈការកែសម្រួលច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ (បារាំង)។

110.25 ធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងសង្គមស៊ីវិលដែលរងផលប៉ះពាល់ ដើម្បីឱ្យច្បាប់ទាំងនេះស្របទៅនឹងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។ (អាល្លឺម៉ង់)

110.26 ធ្វើឱ្យច្បាប់ផ្សេងៗ ដូចជាច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់សហជីព ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ទូរគមនាគមន៍ ស្របទៅនឹងកាតព្វកិច្ចអន្តរជាតិ។ (អ៊ីស្លង់)

110.27 ធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់សហជីព និងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីឱ្យច្បាប់ទាំងនេះស្របនឹងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់រដ្ឋ ដោយធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងសង្គមស៊ីវិលដែលរងផលប៉ះពាល់។ (ណូវែលហ្សេឡង់ដ៍)

110.28 *ការពារអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានា ព្រមទាំងធានាថា បទប្បញ្ញត្តិរដ្ឋបាលនៃច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល មិនត្រូវយកមកប្រើ ដើម្បីបិទ ព្យួរ ឬមិនដូច្នេះទេ ជះឥទ្ធិពលអវិជ្ជមានដល់អង្គការមិនមែនរដ្ឋាភិបាល និងសមាគមនោះឡើយ។* (ស្វីដែន)

110.29 *កែសម្រួលក្រមព្រហ្មទណ្ឌ ក៏ដូចជាច្បាប់ដទៃទៀត រួមទាំងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់សហជីព និងច្បាប់ទូរគមនាគមន៍ ដើម្បីឱ្យច្បាប់ទាំងនេះ ស្របទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។* (ឆែក)

110.30 *លុបចោលច្បាប់វិសោធនកម្មចំនួនពីរ នៃច្បាប់ស្តីពីគណបក្សនយោបាយដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១៧ និងពិនិត្យឡើងវិញនូវច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់សហជីព ដើម្បីធានាថាច្បាប់ទាំងបីនេះ មានសង្គតិភាពជាមួយនឹងកាតព្វកិច្ចរបស់រដ្ឋ ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។* (អូស្ត្រាលី)[៦]

110.31 *កែសម្រួល ឬលុបចោលវិធានការតាមផ្លូវច្បាប់ថ្មីៗដែលមានបំណងជាសក្តានុពល ធ្វើការបកស្រាយតាមទំនើងចិត្តឬបែបវិតក្បិត រួមមានច្បាប់ស្តីពីគណៈបក្សនយោបាយ និងច្បាប់បោះឆ្នោត ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងប្រកាសអន្តរក្រសួងកាលពីខែឧសភា ឆ្នាំ២០១៨ លើប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីធ្វើឱ្យច្បាប់ទាំងនេះស្របទៅនឹងច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។* (អូទ្រីស)[៧]

110.32 *បង្កើតក្រុមការងារដ៏មានប្រសិទ្ធភាពមួយ ទទួលបន្ទុកវិវាទដីធ្លីក្រោមការគាំទ្ររបស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ដោយមានការចូលរួមពីសំណាក់សង្គមស៊ីវិល និងសហភាពអឺរ៉ុប។* (ប្រាវាំង)[៨]

---

[៦] នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

[៧] នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

[៨] នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

110.33 បង្កើតគណៈកម្មាធិការត្រួតពិនិត្យថ្នាក់ជាតិសំរាប់សន្ធិសញ្ញាអន្តរជាតិនានា ដែលកម្ពុជាបានផ្តល់សច្ចាប័នដោយមានការចូលរួមពីអង្គការពលកម្មអន្តរជាតិ។(បារាំង)

110.34 ពន្លឿននីតិវិធីអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ស្របតាមគោលការណ៍ទីក្រុងប៉ារីស (ហុងគ្រី)។

ពន្លឿនការធ្វើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (តូហ្គូ)

110.35 ពន្លឿនការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិស្របតាមគោលការណ៍ទីក្រុងបារីស (អាល់ហ្សេរី), (កូស្តារីកា)

បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ស្របតាមគោលការណ៍ទីក្រុងបារីស។ (ឈីលី)

110.36 បង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស (អូស្ត្រាលី), (ម៉ិចស៊ីកូ)

110.37 បន្តកិច្ចខិតខំប្រឹងប្រែងដល់ការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (នេប៉ាល់)

110.38 បន្តកិច្ចខិតខំប្រឹងប្រែង ចាប់ផ្តើមធ្វើការអំពីស្ថាប័នសិទ្ធិមនុស្សជាតិ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (អ៊ីរ៉ាក់)

110.39 បន្តពង្រឹងកិច្ចខិតខំប្រឹងប្រែង បង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។(ឥណ្ឌូនេស៊ី)

110.40 បន្តអនុវត្តអនុសាសន៍នានា ដែលបានទទួលយកកាលពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ ដែលបានធ្វើកាលពីឆ្នាំ២០១៤ ជាពិសេស ការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ សម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សដោយមានធនធានគ្រប់គ្រាន់។ (អេស្ប៉ាញ)

110.41 ពន្លឿនដំណើរការក្នុងការបញ្ចប់ច្បាប់ស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ស្រប តាមគោលការណ៍ទីក្រុងប៉ារីស។ (ថៃ)

110.42 រក្សាកិច្ចខិតខំប្រឹងប្រែងបន្តទៀត ដើម្បីបង្កើតយន្តការសិទ្ធិមនុស្សជាតិ ស្របតាម គោលការណ៍ទីក្រុងប៉ារីស។ (ទុយនេស៊ី)

110.43 បញ្ចប់ឱ្យបានឆាប់រហ័សនូវនីតិវិធីនានាសំរាប់ការបង្កើតស្ថាប័នសិទ្ធិមនុស្ស ជាតិ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (អ៊ុយក្រែន)

110.44 បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបញ្ចប់ច្បាប់ស្តីពីគណៈកម្មការជាតិសិទ្ធិ មនុស្ស និងធ្វើឱ្យតួនាទីរបស់គណៈកម្មការនេះ មានភាពសកម្ម។ (យ៉េមែន)

110.45 ណែនាំឱ្យប្រើច្បាប់ប្រឆាំងការរើសអើង ដែលជានាការពារ និងហាមឃាត់ យ៉ាងដាក់លាក់នូវការរើសអើងគ្រប់ប្រភេទ រួមទាំងឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ និងចរិកលក្ខណៈភេទ។ (អ៊ីស្លង់)

110.46 ណែនាំឱ្យប្រើច្បាប់ទទួលស្គាល់យេនឌ័រ។ (អ៊ីស្លង់)

110.47 ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីធានាឱ្យមានសមភាពអាពាហ៍ពិពាហ៍ សម្រាប់សហព័ទ្ធដែលមានភេទដូចគ្នា។ (អ៊ីស្លង់)

110.48 បង្កើនកិច្ចខិតខំប្រឹងប្រែង ប្រយុទ្ធនឹងការរើសអើងប្រឆាំងនឹងនិគមជនភាគ តិច និងជាតិសាសន៍ភាគតិច ព្រមទាំងបង្កើតផែនការសកម្មភាពជាតិប្រឆាំងនឹងការរើស អើងពូជសាសន៍។ (តូហ្គូ)

110.49 ពង្រឹងគោលនយោបាយដីធ្លី ដែលបានអនុម័តកាលពីឆ្នាំ២០១៥ ដែលចែង ថាសមភាព និងសមធម៌យេនឌ័ររវាងបុរសនិងស្ត្រី គួរត្រូវបានធានានៅក្នុងដំណើរការនៃ ការចុះបញ្ជីដីធ្លី។ (រដ្ឋពហុជាតិនៃបូលីវី)

110.50 ដោយពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល អនុម័តច្បាប់ និងគោលនយោបាយដែលគ្រប់ជ្រុងជ្រោយប្រឆាំងនឹងការរើសអើង និងអំពើហិង្សាដោយសារទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ និងធានាការអនុវត្តច្បាប់ និងគោលនយោបាយទាំងនេះ នៅក្នុងស្ថាប័នសាធារណៈទាំងអស់ ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និងការងារ។ (ម៉ិចស៊ីកូ)

110.51 ធ្វើវិសោធនកម្មមាត្រា៤៥នៃរដ្ឋធម្មនុញ្ញដើម្បីអនុញ្ញាតឱ្យមានសមភាពអាពាហ៍ពិពាហ៍ស្របច្បាប់ ដោយមានបំណងបន្តនូវការប្រព្រឹត្តដោយស្មើភាព និងពេញលេញ របស់ក្រុមស្រីស្រលាញ់ស្រីដូចគ្នា ប្រុសស្រលាញ់ប្រុស អ្នកស្រលាញ់ទាំងពីរភេទ អ្នកកែភេទ និងអ្នកមានភេទមិនច្បាស់លាស់ នៅគ្រប់វិស័យ។ (ហូឡង់)

110.52 ណែនាំឱ្យប្រើច្បាប់ថ្មីដែលធានាសមភាព និងហាមឃាត់យ៉ាងដាក់លាក់នូវការរើសអើងចំពោះកក្រុមស្រីស្រលាញ់ស្រីដូចគ្នា ប្រុសស្រលាញ់ប្រុស អ្នកស្រលាញ់ ទាំងពីរភេទ អ្នកកែភេទ និងអ្នកមានភេទមិនច្បាស់លាស់។ (ស៊ុយអ៊ែត)

110.53 អនុម័តវិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីប្រយុទ្ធប្រឆាំង និងផ្តន្ទាទោសចំពោះការរើសអើង និងអំពើហិង្សា ដែលបានជំរុញដោយទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ។ (អ៊ុយរុយហ្គាយ)

110.54 ត្រឹមដំណាច់ឆ្នាំ២០២៣ ណែនាំឱ្យប្រើច្បាប់ប្រឆាំងការរើសអើង ដែលធានានូវសមភាព និងហាមឃាត់យ៉ាងដាក់លាក់នូវការរើសអើងគ្រប់ប្រភេទ រួមទាំងការរើងអើងដោយសារសាសនា ទំនោរផ្លូវភេទ អត្តសញ្ញាណនិងការសម្តែងយេនឌ័រ និងចរិកលក្ខណៈភេទ។ (អូស្ត្រាលី)

110.55 ធ្វើវិសោធនកម្មមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតឱ្យសហព័ន្ធមានភេទដូចគ្នារៀបការ។ (កាណាដា)

110.56 បន្តពង្រឹងគោលនយោបាយសង្គមដើម្បីជាប្រយោជន៍ដល់ប្រជាជន ដោយផ្តោតជាពិសេសទៅលើវិស័យនានាដែលងាយរងគ្រោះបំផុត។ (វេណេហ្ស៊ុយអេឡា)។

110.57 បន្តរក្សាស្ថិរភាពសង្គម និងលើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមប្រកបដោយចេរភាពដើម្បីកែលំអស្តង់ដាររស់នៅរបស់ប្រជាជន និងកាត់បន្ថយអត្រាភាពក្រីក្របន្ថែមទៀត។ (ចិន)

110.58 បន្តយន្តការដែលកំពុងអនុវត្តដើម្បីធានាការកាត់បន្ថយភាពក្រីក្រ។ (ឥណ្ឌា)

110.59 បន្តចាត់វិធានការដើម្បីធានាការលុបបំបាត់ភាពក្រីក្រ និងការទទួលបានសេវាសុខាភិបាល និងការអប់រំ។ (ប៉ាគីស្ថាន)

110.60 បន្តកិច្ចខិតខំប្រឹងប្រែងដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ តាមរយៈការអនុវត្តន៍វិធានការនានា ដែលធ្វើឱ្យការអភិវឌ្ឍន៍សេដ្ឋកិច្ចជាក់ស្តែងរបស់ប្រទេស បានជាប្រយោជន៍ដល់គ្រប់ស្រទាប់វណ្ណៈនៃសង្គម។ (ស៊ែប៊ី)

110.61 បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបំពេញនូវសិទ្ធិសេដ្ឋកិច្ចនិងសង្គមរបស់ប្រជាជន ជាពិសេសតាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្នសង្គម។ (សាធារណៈរដ្ឋអ៊ីស្លាមអ៊ីរ៉ង់)

110.62 បន្តអនុវត្តនយោបាយលើកកម្ពស់កំណើនសេដ្ឋកិច្ច និងអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្រឱ្យបានទូលំទូលាយ។ (ម៉ាឡេស៊ី)

110.63 បន្តកិច្ចខិតខំប្រឹងប្រែង ធ្វើឱ្យជឿនលឿនដល់ការលុបបំបាត់ភាពក្រីក្រ ជាពិសេសនៅតំបន់ជនបទ។(គុយបា)

110.64 ចាត់វិធានការបន្ថែមទៀត ដើម្បីគាំពារ និងពង្រឹងវឌ្ឍនភាព ដែលសម្រេចបានក្នុងការកាត់បន្ថយភាពក្រីក្រ។ (វៀតណាម)

110.65 បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយដៃគូនានាបន្ថែមទៀត ដើម្បីអនុវត្តកម្មវិធីផ្សេងៗឱ្យមានប្រសិទ្ធភាព សំដៅដល់ការអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ។ (អាហ្វ៊ីរប៉ៃហ្សង់)

110.66 បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីសម្រេចឱ្យបាននូវគោលដៅទី៣ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ (អាហ្វ៊ីរប៉ៃហ្សង់)

110.67 ខិតខំប្រឹងប្រែងកាន់តែខ្លាំងឡើង ដើម្បីកាត់បន្ថយភាពក្រីក្រ និងសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ (ប៊ូតាន)

110.68 បន្តដោះស្រាយឱ្យមានប្រសិទ្ធភាពនូវភាពងាយរងគ្រោះពិសេស ទស្សនៈ និងតម្រូវការរបស់ស្ត្រី កុមារ ជនពិការ ព្រមទាំងសហគមន៍មូលដ្ឋាន និងសហមគន៍ដែលមិនត្រូវបានយកចិត្តទុកដាក់ នៅពេលអនុវត្តផែនការយុទ្ធសាស្ត្រជាតិរបស់ខ្លួនស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ អំពីសុខភាព និងការប្រែប្រួលអាកាសធាតុ។ (ហ្វីជី)

110.69 បង្កើនកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ (អ៊ីរ៉ាក់)

110.70 បង្កើនកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស រួមទាំងស្ត្រី និងកុមារ។ (ហ្សកហ្ស៊ី)

110.71 ពង្រឹងវិធានការសំដៅបង្ការ និងប្រឆាំងនឹងការជួញដូរមនុស្ស។ (ហុងឌុយរ៉ាស)

110.72 បន្តអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។ (ហ្វីលីពីន)

110.73 ពង្រឹងកិច្ចខិតខំប្រឹងប្រែងអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ដើម្បីបង្ការ និងដោះស្រាយបញ្ហាជួញដូរមនុស្សឱ្យបានកាន់តែប្រសើរ។ (ឥណ្ឌូនេស៊ី)

110.74 បន្តកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ (ទុយនេស៊ី)

110.75 កែលម្អ និងពង្រឹកនីតិវិធីអត្តសញ្ញាណកម្ម និងការការពារដល់ជនរងគ្រោះដោយការជួញដូរមនុស្ស ពលកម្មដោយបង្ខំនិងការងារដោះបំណុល និងធានាការទទួលបានគ្រប់គ្រាន់នូវសេវាគាំទ្រ និងទីជម្រកស្នាក់នៅ។ (សហព័ន្ធជាណាចក្រនៃចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង)

110.76 បន្តបង្កើនសកម្មភាពនានា ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ព្រមទាំងពង្រឹងវិធានការនានា ដើម្បីស្វែងរក បង្ការ និងផ្តន្ទាទោសឧក្រិដ្ឋកម្មបែបនេះ។ (សាធារណៈរដ្ឋបូលីវ៉ារៀននៃវេណេហ្ស៊ុយអេឡា)

110.77 ពង្រឹង និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងផ្តន្ទាទោសអ្នកជួញដូរទាំងនោះ។ (អាល់ហ្សេរី)

110.78 ផ្តល់ឱ្យវិញនូវសិទ្ធិទាំងឡាយដល់សមាជិកគណបក្សប្រឆាំងភ្លាមៗ និងគ្មានលក្ខខណ្ឌ ព្រមទាំងដោះលែងមនុស្សទាំងអស់ ដែលត្រូវបានចាប់ឃុំខ្លួនតាមអំពើចិត្ត រួមទាំង លោក កឹម សុខាផង។ (សហរដ្ឋអាមេរិក)[៩]

110.79 ធ្វើវិសោធនកម្មច្បាប់និងបទប្បញ្ញត្តិនានា ដូចជាច្បាប់ស្តីពីទូរគមនាគមន៍ និងប្រកាសអន្តរក្រសួងស្តីពីការត្រួតពិនិត្យលើការបោះពុម្ពផ្សាយនៃគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គមដំណើរការតាមអ៊ិនធឺណែត ដែលរិតត្បិតយ៉ាងមានប្រសិទ្ធភាពដល់សេរីភាពនៃការបញ្ចេញមតិ ព្រមទាំងបញ្ចប់រាល់ទម្រង់នៃការជ្រៀតជ្រែក និងការតាមដានមើលការនិយាយតាមអនឡាញ និងតាមបណ្តាញផ្សព្វផ្សាយ។ (ហ្វាំងឡង់)[១០]

110.80 ចាត់វិធានការចាំបាច់នានា ដើម្បីអនុញ្ញាតឱ្យសមាជិកគណបក្សប្រឆាំងចូលរួមក្នុងជីវិតនយោបាយកម្ពុជាវិញ។ (បារាំង)

---

៩. នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

១០. នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

110.81 ធានានូវសេរីភាពនៃការបញ្ចេញមតិសម្រាប់ពលរដ្ឋ និងអ្នកសារព័ត៌មានទាំងអស់ រួមទាំងតាមអ៊ិនធឺណែត ដោយធ្វើការកែសម្រួលវិសោធនកម្មរដ្ឋធម្មនុញ្ញលើកចុងក្រោយ និងប្រកាសអន្តរក្រសួងកាលពីខែឧសភា ឆ្នាំ២០១៨ ដែលបានអនុញ្ញាតឱ្យមានការតាមដានមើលមាតិកា/ខ្លឹមសារអត្ថបទតាមអ៊ិនធឺណែត។ (បារាំង)

110.82 ធ្វើឱ្យក្រមព្រហ្មទណ្ឌស្របទៅនឹងមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយលុបចោល ឬធ្វើវិសោធនកម្មមាត្រាទាំងឡាយដែលចែងអំពីបទប្រមាថព្រះមហាក្សត្រ បទបរិហារកេរ្តិ៍ បទប្រមាថ បទញុះញង់ ការបង្ខិតបង្ខំដោយខុសច្បាប់ដល់អាជ្ញាធរតុលាការ និងការបដិសេធសេចក្តីសម្រេចរបស់តុលាការ។ (អាល្លឺម៉ង់)[១១]

110.83 ធានាសេរីភាពនៃការបញ្ចេញមតិតាមអ៊ិនធឺណែត ដោយការលុបចោលសេចក្តីប្រកាសអន្តរក្រសួងលេខ១៧០ ស្តីពីការត្រួតពិនិត្យការបោះពុម្ពផ្សាយតាមគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គមដំណើរការតាមអ៊ិនធឺណែត។ (អាល្លឺម៉ង់)

110.84 លុបចោលបទប្បញ្ញត្តិនានានៃក្រមព្រហ្មទណ្ឌ ដែលអាចត្រូវបានប្រើដើម្បីរឹតត្បិតសេរីភាពនៃការបញ្ចេញមតិ ការប្រមូលផ្តុំ និងសមាគម ព្រមទាំងដាក់ឱ្យទៅជាមិនមែនបទល្មើសព្រហ្មទណ្ឌ ដូចជា បទបរិហារកេរ្តិ៍ជាដើម។ (អ៊ីស្លង់)[១២]

110.85 ចាត់រាល់វិធានការដើម្បីការពារ និងគាំទ្រដល់អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស កម្មករសហជីព សកម្មជនដីធ្លីនិងបរិស្ថាន និងតួអង្គសង្គមស៊ីវិលដទៃទៀត ព្រមទាំងសមាជិកនៃគណបក្សប្រឆាំង។ (អ៊ីស្លង់)

110.86 អនុម័តវិធានការនានាសំដៅដល់ការធានានូវសេរីភាពនៃការបញ្ចេញមតិ និងការទទួលបានសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ប្រជាជន។ (កូឡុំប៊ី)

---

១១. នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

១២. នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

110.87 បង្កើតលក្ខខណ្ឌចាំបាច់ផ្សេងៗ ដើម្បីអនុញ្ញាតឱ្យបុគ្គលគ្រប់រូបទទួលបានសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ជាពិសេស សេរីភាពនៃការបញ្ចេញមតិ សមាគម និងការប្រមូលផ្តុំដោយសន្តិវិធី។ (កូស្តារីកា)

110.88 ស្តារឡើងវិញនូវលំហនយោបាយនិងប្រជាធិបតេយ្យ ដោយធានាឱ្យមានការចូលរួមពីគណបក្សនយោបាយផ្សេងៗ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។ (ណ័រវេស)

110.89 ដោះលែងភ្លាមៗពីការឃុំឃាំងបុគ្គលទាំងឡាយណាដែលត្រូវបានឃុំខ្លួនដោយសារការអនុវត្តសេរីភាពនៃការបញ្ចេញមតិ និងការប្រមូលផ្តុំដោយសន្តិវិធី ព្រមទាំងទម្លាក់ចោលរាល់ការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលទាំងនេះ (ណ័រវេស)[១៣]

110.90 បន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យលំហប្រជាធិបតេយ្យកាន់តែប្រកបដោយបរិយាប័ន្ន។(សាធារណរដ្ឋកូរ៉េ)

110.91 បង្កើតលក្ខខណ្ឌ ដែលអំណោយផលដល់ការពិភាក្សា និងការប្រកួតប្រជែងនយោបាយដោយសេរី ដើម្បីកសាងឡើងវិញនូវលទ្ធិប្រជាធិបតេយ្យមួយ ដែលក្នុងនោះប្រព័ន្ធផ្សព្វផ្សាយ និងសង្គមស៊ីវិល រួមទាំងអ្នកការពារសិទ្ធិមនុស្ស អាចបំពេញការងាររបស់ពួកគេបានដោយសេរី ដោយគ្មានការជ្រៀតជ្រែក ឬរារាំង ដូចដែលបានផ្តល់អនុសាសន៍ដោយប្រទេសអៀកឡង់ដ៍ ក្នុងកំឡុងពេលពិនិត្យកាលពីជុំកន្លងមក ហើយជាពិសេស ដើម្បីធានាថា ការងាររបស់ពួកគេមិនត្រូវបានរារាំងតាមរយៈការរឹតត្បិតទៅលើសេរីភាពនៃការប្រមូលផ្តុំ និងការបញ្ចេញមតិ មិនថានៅក្នុង ឬនៅក្រៅបណ្តាញអ៊ិនធឺណែតឡើយ។ (អៀកឡង់ដ៍)

110.92 កែទម្រង់ក្រមព្រហ្មទណ្ឌ ដើម្បីធានាថា សេរីភាពនៃការបញ្ចេញមតិ ការប្រមូលផ្តុំ និងសមាគម ត្រូវបានធានាការពារ បន្ថែមទៅលើការការពារសិទ្ធិអ្នក

[១៣]. នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

ការពារសិទ្ធិមនុស្ស និងដើម្បីធានាថា អ្នកទាំងនេះអាចបំពេញការងាររបស់ពួកគេដោយគ្មានការភ័យខ្លាចពីការបំភិតបំភ័យ។ (អេស្ប៉ាញ)[១៤]

110.93 ការពារសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស និងធ្វើឱ្យច្បាប់ បទប្បញ្ញត្តិនិងគោលនយោបាយនានា ស្តីពីសេរីភាពនៃការបញ្ចេញមតិ សមាគម និងការប្រមូលផ្តុំ ស្របនឹងកាតព្វកិច្ចអន្តរជាតិរបស់រដ្ឋ។ (អ៊ីតាលី)

110.94 កែសម្រួលការអនុម័ត និងការធ្វើវិសោធនកម្មបទប្បញ្ញត្តិកាលពីពេលថ្មីៗនេះ ដែលរំលោភលើសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងសមាគម រួមទាំងមូលហេតុមិនច្បាស់លាស់ និងទូលំទូលាយពេក សម្រាប់ការបង្ការដល់ការបោះពុម្ពផ្សាយនៅលើអ៊ិនធឺណែត នៅក្នុងប្រកាសស្តីពីការត្រួតពិនិត្យការបោះពុម្ពផ្សាយនៃគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ (ស៊ុយអ៊ែត)

110.95 ធានាថា ពលរដ្ឋទាំងអស់ អាចទទួលបានយ៉ាងពេញលេញនូវសិទ្ធិរបស់ពួកគេ មានសេរីភាពនៃការបញ្ចេញមតិ ការប្រមូលផ្តុំដោយសន្តិវិធី និងសមាគម។ (ស្វីស)

110.96 ធ្វើវិសោធនកម្មច្បាប់ស្តីពីទូរគមនាគមន៍ និងអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានស្របតាមបទដ្ឋានអន្តរជាតិនៃសិទ្ធិមានសេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិជីវិតឯកជន។ (ស្វីស)

110.97 ធ្វើឱ្យដំណើរការឡើងវិញដល់ការបិទប្រព័ន្ធផ្សព្វផ្សាយដោយបង្ខំ និងលុបចោលបទប្បញ្ញត្តិនានានៃក្រមព្រហ្មទណ្ឌដែលដាក់ទោសទណ្ឌលើបទបរិហារកេរ្តិ៍ និងរឹតត្បិតសេរីភាពនៃការបញ្ចេញមតិ និងការប្រមូលផ្តុំ ព្រមទាំងលុបចោលដោយគ្មានលក្ខខណ្ឌនូវបំរាមអតីតសមាជិកនៃគណបក្សសង្គ្រោះជាតិចំនួន១១៨ រូប ពីការចូលរួមក្នុងសកម្មភាពនយោបាយ (សហរាជាណាចក្រនៃចក្រភពអង់គ្លេស និងអៀកឡង់ដ៍)[១៥]

---

[១៤] នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។
[១៥] នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

110.98 *លុបចោលភ្លាមៗរាល់ការរឹតត្បិតដែលមិនសមស្របទៅលើសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ រួមទាំងតាមរយៈការដកចេញនូវសេចក្តីសម្រេចអន្តរក្រសួង គឺប្រកាសលេខ១៧០ ស្តីពីការសម្តែងមតិតាមប្រព័ន្ធឌីជីថល។* (សហរដ្ឋអាមេរិក)

110.99 *ចាត់រាល់វិធានការចាំបាច់ ដើម្បីធានាឱ្យមានបរិយាកាសសុវត្ថិភាពមួយ ដល់ការធានាការពារឱ្យមានការទទួលបានពេញលេញ នូវសេរីភាពនៃការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន និងប្រជាជនទូទៅ ព្រមទាំងស៊ើបអង្កេតនិងដាក់ទោសទណ្ឌរាល់ទម្រង់នៃអំពើហិង្សាប្រឆាំងពួកគេ។* (អាហ្សង់ទីន)

110.100 *ពិចារណាលុបចោលច្បាប់ ដែលអនុញ្ញាតឱ្យមានការរំលាយគណបក្សនយោបាយ និងការហាមប្រាមអ្នកដឹកនាំនយោបាយ ដោយគ្មានដំណើរការត្រឹមត្រូវ។* (ប្រេស៊ីល)[១៦]

118.101 *ចាត់វិធានការដើម្បីការពារសេរីភាពនៃការបញ្ចេញមតិ ទាំងនៅក្នុង និងនៅក្រៅប្រព័ន្ធអ៊ិនធឺណែត ព្រមទាំងសេរីភាពខាងសមាគម និងការប្រមូលផ្តុំ។* (ប្រេស៊ីល)

110.102 *ពង្រឹងការចូលរួមបែបប្រជាធិបតេយ្យ តាមរយៈការធានាឯករាជ្យភាពនៃប្រព័ន្ធផ្សព្វផ្សាយ និងការបង្កើតបរិយាកាសសុវត្ថិភាពនិងអំណោយផលដល់សង្គមស៊ីវិល និងសហជីព ព្រមទាំងតាមរយៈការជំរុញឱ្យមានការចូលរួមពេញលេញរបស់គណបក្សប្រឆាំងក្នុងការបោះឆ្នោតឃុំ/សង្កាត់ ព្រឹទ្ធសភា និងរដ្ឋសភានៅអាណត្តិក្រោយ។* (កាណាដា)

110.103 *លើកកម្ពស់កិច្ចសន្ទនាក្នុងចំណោមតួអង្គនយោបាយ សេរីភាព និងសិទ្ធិរបស់ប្រជាជន និងដំណើរការប្រជាធិបតេយ្យ ដើម្បីបង្រួបបង្រួមប្រជាជនឆ្ពោះទៅរកការអភិវឌ្ឍន៍។ នៅក្នុងដំណើរការនេះ ត្រូវធានាឱ្យបាននូវបរិយាកាសដែលសិទ្ធិរបស់តួអង្គនយោបាយទាំងអស់ សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងតួអង្គផ្សេងទៀត ត្រូវបានគោរព ហើយសកម្មភាពរបស់ពួកគេមិនត្រូវបានបង្អាប់បញ្ជា។* (ជប៉ុន)

---

[១៦] នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

110.104 បង្កើតគណបក្សប្រឆាំងឡើងវិញ គឺគណបក្សសង្គ្រោះជាតិ និងផ្តល់ឱ្យសមាជិករបស់គណបក្សនេះ ដំណើរការវិញ។ (កាណាដា)[១៧]

110.105 ធ្វើឱ្យច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយស្តីពីសេរីភាពនៃការបញ្ចេញមតិ សមាគមនិងការប្រមូលផ្តុំជាសាធារណៈ ស្របតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ (ដាណឺម៉ាក)

110.106 ខិតខំប្រឹងប្រែងទ្វេដងដើម្បីការពារសេរីភាពនៃគំនិត និងការបញ្ចេញមតិ ទាំងក្នុង និងក្រៅប្រព័ន្ធអ៊ិនធឺណែត ដើម្បីធានា និងលើកកម្ពស់បរិយាកាសមួយប្រកបដោយសុវត្ថិភាព សម្រាប់អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងបក្សប្រឆាំង ព្រមទាំងស៊ើបអង្កេតយ៉ាងមានប្រសិទ្ធភាព និងយ៉ាងហ្មត់ចត់ទៅលើគ្រប់ករណីវាយប្រហារប្រឆាំងនឹងអ្នកទាំងនោះ។ (លីទុយអានី)

110.107 ចាត់វិធានការចាំបាច់ ដើម្បីធានាថា សិទ្ធិសេរីភាពនៃការប្រមូលផ្តុំ និងសមាគម មិនត្រូវបានរារាំងដោយការរឹតត្បិតតាមទំនើងចិត្ត និង/ឬការប្រើប្រាស់កម្លាំងលើសលុបនោះទេ។ (លីទុយអានី)

110.108 លុបចោលការចុះបញ្ជីសហជីព និងលក្ខខណ្ឌតម្រូវនៃការធ្វើរបាយការណ៍ ដែលនាំឱ្យមានការរឹតត្បិតដល់សេរីភាពខាងសមាគម ការប្រមូលផ្តុំនិងការបញ្ចេញមតិ។ (គ្រិក)[១៨]

110.109 បញ្ឈប់រាល់ការយាយី និងការជ្រៀតជ្រែកតាមទំនើងចិត្ត ទៅលើការប្រឆាំងផ្នែកនយោបាយ អ្នកការពារសិទ្ធិមនុស្ស និងសកម្មជនការងារ ព្រមទាំងធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិនានាដែលត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព ដើម្បីដាក់កំហិតដល់សេរីភាពខាងសមាគម និងការប្រមូលផ្តុំ ដូចជា បទប្បញ្ញត្តិមួយចំនួននៅក្នុងច្បាប់ស្តី

[១៧]. នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។
[១៨]. នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

*ពីគណបក្សនយោបាយ ច្បាប់ស្ដីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្ដីពីសហជីពជាដើម។ (ហ្វាំងឡង់)*

110.110 *ធានាឱ្យមានលំហពលរដ្ឋសេរីមួយ ដោយអនុញ្ញាតឱ្យក្រុមអ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន សម្ដែងពីខ្លួនគេដោយសេរីទាំងក្នុង និងក្រៅប្រព័ន្ធអ៊ិនធឺណែត ដោយគ្មានការភ័យខ្លាចពីការយាយី ឬការសងសឹក និងបញ្ឈប់ការផ្ដន្ទាទោសអ្នកទាំងឡាយដែលអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ដោយក្រមព្រហ្មទណ្ឌ និងច្បាប់ស្ដីពីទូរគមនាគមន៍។ (ប្រទេសហូឡង់)*

110.111 *ដោះលែងអ្នកទោសនយោបាយនិងអ្នកប្រឆាំងដែលនៅសេសសល់ទាំងអស់ជាបន្ទាន់និងគ្មានលក្ខខណ្ឌ និងទម្លាក់ចោលរាល់ការចោទប្រកាន់ប្រឆាំងនឹងពួកគេ រួមទាំងការដោះលែងលោក កឹម សុខា មេដឹកនាំប្រឆាំង ឱ្យមានសេរីភាពពេញលេញឡើងវិញ។ (ណូវែលហ្សេឡង់)*[១៩]

110.112 *បញ្ចប់ការយាយី និងការចាប់ខ្លួនតាមទំនើងចិត្ត នៃអ្នកការពារសិទ្ធិមនុស្ស សមាជិកគណបក្សប្រឆាំង សកម្មជននានា និងអ្នកសារព័ត៌មាន។ (ក្រូអាត)*

110.113 *ការពារអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស សមាជិកគណបក្សប្រឆាំង និងកម្មករសហជីព ពីការយាយី ការចាប់ខ្លួនតាមទំនើងចិត្ត និងការវាយប្រហារលើរូបរាងកាយ ព្រមទាំងស៊ើបអង្កេត និងផ្ដន្ទាទោសជនល្មើសនៃអំពើវាយប្រហារបែបនេះ។ (ស្វុយដែ)*

110.114 *បង្កើនកិច្ចខិតខំប្រឹងប្រែងបង្ការការយាយីចំពោះអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន កម្មករសហជីព អ្នកតវ៉ា សកម្មជនដីធ្លី និងតួអង្គសង្គមស៊ីវិលដទៃទៀត ព្រមទាំងការពារសិទ្ធិរបស់ពួកគេ។ (ឆែក)*

---

[១៩] នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

110.115 *អនុម័តវិធានការចាំបាច់ដើម្បីធានាការពារសិទ្ធិរបស់អ្នកទាំងឡាយដែលធ្វើការដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្ស ជាពិសេស អ្នកការពារសិទ្ធិមនុស្ស និងស៊ើបអង្កេតនិងផ្តន្ទាទោសអ្នកដែលទទួលខុសត្រូវចំពោះការគំរាមកំហែង និងការប្រើអំពើហិង្សាលើពួកគេ និងគ្រួសាររបស់ពួកគេ។* (អាហ្សង់ទីន)

110.116 *អនុម័តវិធានការចាំបាច់ដើម្បីការពារសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស សកម្មជនសហជីព និងអ្នកសារព័ត៌មាន។*(ឈីលី)

110.117 *បង្កើតបរិយាកាសអំណោយផលមួយសម្រាប់ប្រព័ន្ធផ្សព្វផ្សាយសេរី និងពហុភាព រួមទាំងតាមរយៈការបញ្ឈប់ការឃាយឃីតាមផ្លូវតុលាការប្រឆាំងនឹងអ្នកសារព័ត៌មាន និងការយកករណីរំលោភលើច្បាប់ពន្ធដារ ដើម្បីឃាយឃីដល់ប្រព័ន្ធផ្សព្វផ្សាយ និងសមាគមនានា។* (ក្រិក)[២០]

110.118 *បន្តអនុវត្តវិធានការនានា ដើម្បីពង្រឹងឯករាជ្យភាពទាំងប្រព័ន្ធតុលាការ និងប្រព័ន្ធផ្សព្វផ្សាយ។* (អ៊ីតាលី)

110.119 *បញ្ឈប់ការប្រើអំណាចលើសលុបពីអង្គនីតិប្រតិបត្តិឱ្យមានឥទ្ធិពលទៅលើការងាររបស់ចៅក្រម និងព្រះរាជអាជ្ញា តាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។* (អាល្លឺម៉ង់)[២១]

110.120 *បង្កើតសាលាឧទ្ធរណ៍តំបន់ស្របទៅតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងធានាពីដំណើរប្រតិបត្តិការដ៏ត្រឹមត្រូវរបស់តុលាការនេះ នៅត្រឹមឆ្នាំ២០២៣។* (ក្រិក)

---

[២០] នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

[២១] នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

110.121 បង្កើយដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដោយផ្តល់ការការពារឯករាជ្យភាព និងអនាគតនៃប្រព័ន្ធតុលាការ មន្ត្រីតុលាការនិងចៅក្រម ឱ្យស្របទៅតាមបទដ្ឋានអន្តរជាតិ។ (ណ័រវេស)[២២]

110.122 ចាត់វាល់វិធានការចាំបាច់ដើម្បីពង្រឹងនីតិរដ្ឋ និងធានាឯករាជ្យភាពតុលាការឱ្យបានពេញលេញ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ (លីទុយអានី)

110.123 ប្រកាន់ខ្ជាប់នូវបទដ្ឋានអន្តរជាតិស្តីពីឯករាជ្យភាពស្ថាប័នដូចជាតុលាការ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីធានាថា ដំណើរការបោះឆ្នោតមានលក្ខណៈសេរី ត្រឹមត្រូវ និងមានតម្លាភាព។ (អៀកឡង់ដ៍)

110.124 ធ្វើឱ្យជឿនលឿនថែមទៀតនូវកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងបង្កើតប្រព័ន្ធតុលាការឯករាជ្យមួយ ដែលត្រូវបានប្រជាជនជឿជាក់ និងប្រើប្រាស់។ ដើម្បីធ្វើឱ្យសម្រេចបានគោលបំណងនេះ ត្រូវប្រើប្រាស់ជាអតិបរិមានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើជាគំរូ។ (ជប៉ុន)

110.125 ពង្រឹងឯករាជ្យភាពនិងការប្រព្រឹត្តទៅរបស់តុលាការ ជាពិសេសតាមរយៈការលុបចោល ឬការធ្វើវិសោធនកម្មដ៏ចាំបាច់នូវច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ (អូទ្រីស)

110.126 ចាត់វាល់វិធានការចាំបាច់ ឆ្ពោះទៅរកការកាត់បន្ថយជាដំកំកួនក្នុងរយៈពេលដែលបុគ្គលម្នាក់ៗត្រូវចំណាយនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន។ (អូទ្រីស)

110.127 ធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា ព្រមទាំងការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីធានា និងការពារឯករាជ្យភាពរបស់តុលាការ។ (បែលហ្ស៊ិក)

---

[២២] នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

110.128 បន្តកិច្ចខិតខំប្រឹងប្រែងដ៏គួរឱ្យកត់សំគាល់របស់ខ្លួនដើម្បីលើកកម្ពស់ និង ការពារសិទ្ធិមនុស្ស តាមរយៈការប្តេជ្ញាចិត្តដ៏មុតមាំចំពោះអភិបាលកិច្ចល្អ តម្លាភាព ការ ចូលរួមរបស់សាធារណជនក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច និងការទទួលបាន យុត្តិធម៌។ (តួកគី)

110.129 ចាត់វិធានការបន្ថែមទៀត ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ តាមរយៈការ ពង្រឹងគណនេយ្យភាព និងសមត្ថភាពស្ថាប័ន។ (ប៊ូតាន)

110.130 បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងបញ្ហាដីធ្លី រួមទាំង តាមរយៈការអនុវត្តន៍វិធានការ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ដើម្បីដោះស្រាយពីការបណ្តេញចេញពីដីធ្លី និងផ្តល់ សំណងឱ្យបានត្រឹមត្រូវដល់ជនរងគ្រោះពីការរំលោភយកដីធ្លី ជាពិសេស ដល់ជនជាតិដើម ភាគតិច។ (អ៊ីតាលី)

110.131 ធានាថា ជនរងគ្រោះពីការរំលោភយកដីធ្លី ត្រូវទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌ និងតាមការសមស្រប ទទួលបានសំណងសមរម្យ និងការទទួលបានយុត្តិ ធម៌ដោយគ្មានការរើសអើង។ (ស្វីស)

110.132 ជម្នះឧបសគ្គនានា ដើម្បីទទួលបានយុត្តិធម៌សម្រាប់ស្ត្រីជនរងគ្រោះពី អំពើហិង្សា។ (អ៊ីរ៉ាក់)

1180133 ធានាឱ្យបាននូវគណនេយ្យភាព ចំពោះការរំលោភបំពានសិទ្ធិមនុស្ស តាមរយៈការស៊ើបអង្កេតឯករាជ្យ និងការផ្តន្ទាទោសជនល្មើស។ (អ៊ុយក្រែន)

110.134 អនុវត្តយន្តការសំណងសម្រាប់ជនរងគ្រោះពីអំពើប្រល័យពូជសាសន៍។ (ស្វីស)

110.135 ពង្រឹងកិច្ចខិតខំប្រឹងប្រែង ធានាការចុះបញ្ជីសំបុត្រកំណើតដល់មនុស្ស គ្រប់រូបដែលកើតនៅកម្ពុជា រួមទាំងជនជាតិភាគតិច និងប្រជាជនដែលពិបាកទៅដល់ ដូចជាសហគមន៍នៅតាមព្រំដែនជាដើម។ (ម៉ិកស៊ិក្ស)

110.136 អនុម័តរាល់វិធានការចាំបាច់ ដើម្បីធានាថា អ្នកដែលកើតនៅកម្ពុជាអាចទទួលបានសញ្ជាតិខ្មែរ ហើយថាពួកគេអាចទទួលបានលិខិតបញ្ជាក់ពីអត្តសញ្ញាណ។ (អេស្ប៉ាញ)

110.137 បង្កើតលក្ខខណ្ឌសម្រាប់ប្រជាធិបតេយ្យពហុបក្សពិតប្រាកដនៅក្នុងប្រទេស និងសម្រាប់រៀបចំការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ។ (ក្រិក)[២៣]

110.138 បន្តកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងវិស័យកំណែទម្រង់ការបោះឆ្នោត។(ប៊ូតាន)

110.139 បន្តការងារ ដើម្បីរក្សាដំណើរការបោះឆ្នោតបែបពហុបក្ស។ (ឈីលី)

110.140 ចាត់វិធានការដើម្បីលើកកម្ពស់សិទ្ធិទទួលបានការអប់រំ និងការថែទាំសុខភាពដោយមិនបង់ថ្លៃ ជាពិសេស នៅតាមតំបន់ជនបទ។ (ប៉ាគីស្ថាន)

110.141 បង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីធានានូវសិទ្ធិសង្គមកិច្ច និងសេដ្ឋកិច្ចរបស់ពលរដ្ឋទូទាំងប្រទេស។ (សហព័ន្ធរុស្ស៊ី)

110.142 អនុវត្តសកម្មភាពនានា ដើម្បីបន្តកែលំអគុណភាព និងការទទួលបានសេវាថែទាំសុខភាព និងការអប់រំ ប្រកបដោយសមធម៌។ (គុយបា)

110.143 ចាត់វិធានការបន្ថែមទៀតដើម្បីបំពេញគម្លាតនៃការអភិវឌ្ឍន៍ និងកែលំអការទទួលបានការអប់រំ និងសេវាថែទាំសុខភាព ជាពិសេស សម្រាប់ប្រជាជននៅតាមតំបន់ជនបទ ដើម្បីធានាថា គ្មាននរណាម្នាក់ត្រូវបានគេទុកចោលនោះទេ។ (ថៃ)

110.144 បន្តកិច្ចខិតខំប្រឹងប្រែងសំដៅលើកកម្ពស់ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ព្រមទាំងធ្វើឱ្យការអប់រំមានដល់ពលរដ្ឋទាំងអស់។ (អេហ្ស៊ីប)

110.145 ចាត់វិធានការបន្ថែមទៀត ដើម្បីផ្តល់សិទ្ធិទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា តាមរយៈការបង្កើនសេវាអប់រំប្រកបដោយសមធម៌ដល់កុមារនិងយុវជនទាំងអស់ទាំងនៅក្នុងការអប់រំក្នុងប្រព័ន្ធ និងការអប់រំក្រៅប្រព័ន្ធ។ (ឥណ្ឌូនេស៊ី)

[២៣]. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

110.146 បន្តធ្វើឱ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំនៅគ្រប់សាលាបណ្ដុះបណ្ដាលជំនាញ និងវិជ្ជាជីវៈទូទៅ។ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ)

110.147 បន្តវិធានការនានា ដែលពង្រីកដល់វិស័យសង្គម និងថែទាំសុខភាព។ (ស៊ែប៊ី)

110.148 ការពារសិទ្ធិរបស់កសិករ និងអ្នកផ្សេងទៀត ដែលកំពុងធ្វើការនៅតាមតំបន់ជនបទ រួមទាំងតាមរយៈការធានាថា ពួកគេត្រូវទទួលបានសំណងសមរម្យក្នុងករណីនៃការតាំងលំនៅថ្មី។ (ព័រទុយហ្គាល់)

110.149 អនុម័តវិធានការនានា ដើម្បីទប់ស្កាត់ការបណ្ដេញប្រជាជនកម្ពុជាចេញពីដីរបស់ពួកគេដោយខុសច្បាប់ និងប្រើប្រាស់យន្តការផ្អែកលើគណនេយ្យភាព និងតម្លាភាព ដើម្បីដោះស្រាយវិវាទដីធ្លីប្រកបដោយសមភាព និងឆាប់រហ័ស ដូចដែលបានជំរុញដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅក្នុងសេចក្ដីសម្រេចលេខ ៣៦/៣២ របស់ខ្លួន ដែលត្រូវបានអនុម័តជាឯកច្ឆ័ន្ទ។ (កាណាដា)[២៤]

110.150 បន្តការផ្ដួចផ្ដើមជាវិជ្ជមាន ដើម្បីសម្របសម្រួលការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋក្រីក្រ។ (រដ្ឋពហុជាតិនៃបូលីវី)

110.151 ធានាថា សិទ្ធិសហជីពរបស់កម្មករ ត្រូវបានធានាស្របតាមអនុសញ្ញាអង្គការពលកម្មអន្តរជាតិដែលពាក់ព័ន្ធ ហើយថាសហជីពអាចចុះបញ្ជីដោយគ្មានការរារាំង និងធ្វើជាតំណាងឱ្យសមាជិករបស់ពួកគេ។ (ស៊ុយអែត)

110.152 ដូចដែលរដ្ឋាភិបាលបានប្ដេជ្ញាចិត្តកាលពីលើកមុន បន្ទាប់ពីការពិនិត្យមើលកាលពីជុំទី២ ធ្វើឱ្យមានភាពងាយស្រួល និងកែទម្រង់នីតិវិធីចុះបញ្ជីសម្រាប់សហជីព និងអង្គការសង្គមស៊ីវិលដទៃទៀត។ (សហរដ្ឋអាមេរិក)

[២៤] នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

110.153 ធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីព ដោយធ្វើការពិគ្រោះយោបល់ជាមួយកម្មករ អ្នកតស៊ូមតិខាងការងារ និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីឱ្យច្បាប់នេះស្របទាំងស្រុងទៅនឹងអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ៨៧ និង៩៨។ (បែលហ្សិក)

110.154 បន្តគោលនយោបាយ និងកម្មវិធីដែលកំពុងអនុវត្ត ដើម្បីធានាគុណភាពការថែទាំសុខភាពសម្រាប់ទាំងអស់គ្នា។ (ឥណ្ឌា)

110.155 បន្តផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០១៦-២០២០ របស់ក្រសួងសុខាភិបាលកម្ពុជា ដើម្បីធានាថា ប្រជាពលរដ្ឋទទួលបានសេវាថែទាំសុខភាពពេញលេញ។ (មីយ៉ាន់ម៉ា)

110.156 អនុម័តអភិក្រមសុខាភិបាលសាធារណៈ និងសិទ្ធិមនុស្ស ចំពោះបញ្ហាគ្រឿងញៀន រួមទាំង ការមិនដាក់ទោសព្រហ្មទណ្ឌចំពោះការប្រើប្រាស់គ្រឿងញៀន ព្រមទាំងធ្វើការផ្តល់សេវាកាត់បន្ថយគ្រោះថ្នាក់។ (ព័រទុយហ្គាល់)

110.157 បន្តវិនិយោគក្នុងការកែលំអហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលសាធារណៈរបស់ខ្លួន ជាពិសេសនៅតាមតំបន់ជនបទ ដើម្បីធានាឱ្យមានការអនុវត្តន៍ផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០១៦-២០២០ របស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ (សិង្ហបុរី)

110.158 បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីកែលំអហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាពជារួម និងធានាឱ្យមានការទទួលបានកាន់តែងាយស្រួលនូវប្រព័ន្ធសុខាភិបាលសាធារណៈ និងសេវាគាំពារមាតុភាពសម្រាប់ស្ត្រីជាពិសេស។ (សាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់)

110.159 គាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីទប់ស្កាត់ជំងឺរបេង និងធានាថាគោលនយោបាយពាក់ព័ន្ធសំដៅដល់ការលុបបំបាត់ជំងឺរបេងទាំងស្រុង ត្រូវបានអនុវត្តយ៉ាងពេញលេញ។ (ម៉ាឡេស៊ី)

110.160 *អនុវត្តយ៉ាងពេញលេញនូវគោលនយោបាយពាក់ព័ន្ធ និងចែករំលែកការអនុវត្តន៍ល្អៗក្នុងការប្រយុទ្ធប្រឆាំងជំងឺរបេង និងហ៊ីវ/អេដស៍ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ)*

110.161 *បន្តអភិវឌ្ឍន៍វិស័យអប់រំឱ្យបានខ្លាំងក្លា ដើម្បីធានាឱ្យបានកាន់តែប្រសើរដល់សិទ្ធិរបស់ប្រជាជនទទួលបានការអប់រំ។ (ចិន)*

110.162 *បន្តវិធានការដែលកំពុងអនុវត្ត ដើម្បីលើកកម្ពស់ការអប់រំសម្រាប់ទាំងអស់គ្នា។ (ឥណ្ឌា)*

110.163 *បន្តការអនុវត្តន៍ច្បាប់ពាក់ព័ន្ធ ដើម្បីធានាថាប្រជាពលរដ្ឋទាំងអស់ទទួលបានការអប់រំដោយឥតបង់ថ្លៃនៅបឋមសិក្សា និងមធ្យមសិក្សានៅតាមសាលារដ្ឋ ហើយថា ប្រជាពលរដ្ឋទាំងអស់អាចទទួលបានការអប់រំយ៉ាងហោចប្រាំបួនឆ្នាំ។ (មីយ៉ាន់ម៉ា)*

110.164 *បន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយសមធម៌ដល់កុមារទាំងអស់ តាមរយៈការអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ។ (ប៉ាគីស្ថាន)*

110.165 *បន្តកិច្ចខិតខំប្រឹងប្រែងដើម្បីធានានូវការអប់រំមូលដ្ឋានដោយឥតបង់ថ្លៃនិងជាសកល ជាមួយនឹងវិធានការប្រកបដោយបរិយាប័ន្ន ជាពិសេស សម្រាប់ក្រុមងាយរងគ្រោះ។ (សាធារណៈរដ្ឋកូរ៉េ)*

110.166 *កសាងធនធានមនុស្ស និងហិរញ្ញវត្ថុ ដើម្បីធានាដល់ការចុះឈ្មោះចូលរៀនសម្រាប់ទាំងអស់គ្នា នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ (សេណេហ្គាល់)*

110.167 *វិនិយោគក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីធានាពីចំណេះ និងជំនាញរបស់ពួកគាត់ឱ្យនៅតែទាន់សម័យ និងដើម្បីបង្កើនគុណភាពនៃការបង្រៀនរបស់ពួកគាត់។ (សិង្ហបុរី)*

110.168 បន្តខិតខំប្រឹងប្រែង ដើម្បីធានានូវសិទ្ធិទទួលបានការអប់រំកម្រិតបឋមសិក្សាទៅជាកាតព្វកិច្ច មិនបង់ថ្លៃ និងប្រកបដោយបរិយាប័ន្ន។ (ទុយនីស៊ី)

110.169 បន្តការខិតខំប្រឹងប្រែងដើម្បីធានានូវការអប់រំសម្រាប់ទាំងអស់គ្នាប្រកបដោយបរិយាប័ន្ន និងគុណភាពប្រកបដោយសមធម៌។ (វៀតណាម)

110.170 បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្ថែមទៀត ដើម្បីកែលំអគុណភាពអប់រំ និងលើកកម្ពស់កម្មវិធីសំរាប់ការទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា ជាពិសេសការអប់រំនៅកម្រិតបឋមសិក្សា (សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ)

110.171 ពង្រឹកកិច្ចប្រឹងប្រែងកែលំអសិទ្ធិមនុស្សសម្រាប់ស្ត្រី និងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ និងការធ្វើអាជីវកម្មលើស្ត្រី និងកុមារ។ (ណ័រវេស)

110.172 លុបចោលការហាមប្រាមដែលមានលក្ខណៈរើសអើងចំពោះស្ត្រីដែលចង់រៀបការម្តងទៀតក្នុងរយៈពេល១២០ថ្ងៃ បន្ទាប់ពីការលែងលះ ឬទុកជាមោឃៈ។ (អ៊ីស្លង់)

110.173 បន្តយន្តការកំពុងអនុវត្ត សម្រាប់ភាពស្មើគ្នាខាងយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី។ (ឥណ្ឌា)

110.174 បន្តអនុវត្តគោលនយោបាយសមភាពយេនឌ័រ ដើម្បីធានាការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យ និងកម្មវិធីទាំងអស់។ (ប៉ាគីស្ថាន)

110.175 ពង្រឹងបន្ថែមទៀតនូវកម្មវិធីដោះស្រាយការរើសអើងប្រឆាំងស្ត្រី និងក្មេងស្រី និងលើកកម្ពស់សមភាពយេនឌ័រ។ (ហ្វីលីពីន)

110.176 បន្តអនុវត្តគោលនយោបាយសមភាពយេនឌ័រ តាមរយៈការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យ និងកម្មវិធីទាំងអស់។ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ)

110.177 បង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដង ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ក្នុងវិស័យច្បាប់ និងបញ្ចប់ការអនុវត្តន៍ដ៏គ្រោះថ្នាក់ និងផ្នត់គំនិតមានលក្ខណៈរើសអើង ដែលធ្វើឱ្យស្ត្រីកម្ពុជាក្លាយជាជនរងគ្រោះ។ (អ៊ុយរុយហ្គាយ)

110.178 បន្តអនុវត្តវិធានការនានា សំដៅដល់ការលើកកម្ពស់សិទ្ធិស្ត្រី រួមទាំងការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី។ (ម៉ាល់ឌីវ)

110.179 ធានានូវកិច្ចខិតខំប្រឹងប្រែង ដើម្បីលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សា និងការរើសអើងដោយហេតុផលយេនឌ័រ ព្រមទាំងធានានូវការផ្ដល់អំណាចដល់ក្រុមងាយរងគ្រោះទាំងអស់។ (នេប៉ាល់)

110.180 ពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីការពារសិទ្ធិរបស់ក្រុមងាយរងគ្រោះបំផុត ដូចជា ស្ត្រី កុមារ និងជនពិការ ព្រមទាំងដើម្បីបង្ការ និងប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ និងអាជីវកម្មផ្លូវភេទក៏ដូចជាទម្រង់ដទៃទៀតនៃអំពើហិង្សា រួមទាំងអំពើហិង្សាក្នុងគ្រួសារផងដែរ។ (អ៊ីតាលី)

110.181 ពង្រឹងតួនាទី និងឋានៈរបស់ស្ត្រី ព្រមទាំងលើកកម្ពស់ និងការពារសិទ្ធិកុមារ និងជនពិការក្នុងសង្គម។ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ)

110.182 ផ្ដល់វគ្គបណ្ដុះបណ្ដាលជាកាតព្វកិច្ចស្ដីពីនីតិវិធីផ្ដន្ទាទោសលើករណីនៃអំពើហិង្សាយេនឌ័រ ដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការ។ (សាធារណៈរដ្ឋម៉ុលដូវ៉ា)

110.183 បែងចែកធនធានមនុស្ស និងហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ ដើម្បីបង្កើតមជ្ឈមណ្ឌលសេវាកម្មច្រកចេញចូលតែមួយ ឱ្យបានយ៉ាងតិច ៥មណ្ឌល នៅត្រឹមឆ្នាំ២០២៤ ដើម្បីផ្ដល់សេវាគាំទ្រដោយឥតគិតថ្លៃដល់ជនរងគ្រោះពីអំពើហិង្សាយេនឌ័រ។ (អូស្ត្រាលី)

110.184 ធ្វើការស៊ើបអង្កេតឱ្យបានគ្រប់ជ្រុងជ្រោយ អំពីករណីនៃអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ ព្រមទាំងធានាថា ជនល្មើសត្រូវបានផ្ដន្ទាទោស ហើយជនរងគ្រោះត្រូវទទួលបានសំណងសមរម្យ។ (សាធារណរដ្ឋម៉ុលដូវ៉ា)

110.185 ផ្ដើកំណែទម្រង់ច្បាប់ជាតិ ដើម្បីពង្រឹងកិច្ចការពារដល់ស្ត្រី និងកុមារពីអំពើហិង្សាក្នុងគ្រួសារ។ (សហព័ន្ធរុស្ស៊ី)

110.186 ពង្រឹងយន្តការតុលាការដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាគ្រួសារ និងការជួញដូរមនុស្ស ព្រមទាំងអនុវត្តកម្មវិធីលើកកម្ពស់ការយល់ដឹង និងការអប់រំអំពីបញ្ហាទាំងនេះ។ (តូហ្គូ)

110.187 បង្កើតវិធានការជាក់ស្ដែង សំដៅធានាឱ្យមានការរក្សាដ៏មានប្រសិទ្ធភាពនូវអាត្រាក្មេងស្រីនៅសាលារៀន។ (ដាណឺម៉ាក)

110.188 ដាក់ទោសទណ្ឌឱ្យបានច្បាស់លាស់ចំពោះការជ្រើសរើស និងការប្រើប្រាស់ក្មេងអាយុក្រោម១៨ឆ្នាំ នៅក្នុងជម្លោះប្រដាប់អាវុធ និងក្រុមប្រដាប់អាវុធនានាដែលមិនមែនជារបស់រដ្ឋ។ (ម៉ុងតេណេក្រូ)[២៥]

110.189 ចាត់វាល់វិធានការសមស្រប ដើម្បីការពារកុមារពីអាជីវកម្មផ្លូវភេទ ជាពិសេសនៅក្នុងបរិបទនៃ "ទេសចរកុមារកំព្រា" រួមទាំងតាមរយៈការពង្រឹងក្របខណ្ឌច្បាប់របស់ខ្លួន និងវិធានការបង្កើនការយល់ដឹង ព្រមទាំងតាមរយៈការធានាថា គ្រប់បទចោទប្រកាន់ត្រូវបានស៊ើបអង្កេត ជនរងគ្រោះត្រូវបានជួសជុលសំណង ហើយជនល្មើសត្រូវបានផ្ដន្ទាទោស។(ព័រទុយហ្គាល់)

110.190 អនុវត្តអាយុស្របច្បាប់សម្រាប់អាពាហ៍ពិពាហ៍ ដើម្បីហាមឃាត់ការរៀបអាពាហ៍ពិពាហ៍កុមារ និងលើកកម្ពស់យុទ្ធនាការបង្កើនការយល់ដឹង ដើម្បីទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ។ (ព័រទុយហ្គាល់)

110.191 ហាមឃាត់តាមផ្លូវច្បាប់នូវការជួញដូរផ្លូវភេទកុមារ នៅក្នុងបរិបទនៃផែនការសកម្មភាពជាតិថ្មីសម្រាប់ការលុបបំបាត់ការជួញដូរ និងការរត់ពន្ធមនុស្ស អាជីវកម្មលើពលករ និងអាជីវកម្មផ្លូវភេទដោយខុសច្បាប់។ (អេស្ប៉ាញ)

---
[២៥] នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

110.192 *បន្តពង្រឹងច្បាប់ និងយន្តការនានា ដែលហាមឃាត់រាល់ទម្រង់នៃការប្រព្រឹត្តមិនគប្បីលើកុមារ និងដែលការពារពួកគេពីពលកម្មដោយបង្ខំ អាជីវកម្ម និងការរំលោភបំពានផ្លូវភេទ។ (ប្រ៊ុយណេដារូសាឡឹម)*

110.193 *បន្តធានាការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនៃផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ សំរាប់ឆ្នាំ២០១៦-២០២៥។ (ម៉ាល់ឌីវ)*

110.194 *ធ្វើវិសោធនកម្មច្បាប់ជាតិ ដើម្បីធានាថា ច្បាប់នោះស្របនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដោយយកចិត្តទុកដាក់ជាពិសេសទៅលើបទប្បញ្ញត្តិនានានៃក្រមព្រហ្មទណ្ឌ និងប្រព័ន្ធយុត្តិធម៌អនីតិជន។ (អ៊ុយរុយហ្គាយ)*

110.195 *បន្តកិច្ចខិតខំប្រឹងប្រែងលើកកំពស់ការចូលរួមរបស់ជនពិការ។ (ហ្វីលីពីន)*

110.196 *អនុវត្តវិសាលភាពស្របច្បាប់ដែលចាំបាច់នៅក្នុងវិស័យនៃការការពារជនពិការ ជាពិសេសដើម្បីការពារតម្រូវការសុខភាព និងខាងផ្នែកអប់រំសង្គមរបស់ពួកគេជាពិសេស តម្រូវការណាដែលចាំបាច់បំផុត។ (អេស្ប៉ាញ)*

110.197 *កាត់បន្ថយភាពក្រីក្រក្នុងចំណោមជនពិការនិងពង្រឹងដល់ពួកគេឱ្យទទួលបានរបបបេឡាជាតិសន្តិសុខសង្គម នៅឆ្នាំខាងមុខៗ។ (សាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់)*

110.198 *បន្តលើកកម្ពស់សិទ្ធិជនពិការ តាមរយៈផែនការយុទ្ធសាស្ត្រជាតិរបស់រដ្ឋាភិបាល។ (ប្រ៊ុយណេដារូសាឡឹម)*

111. សេចក្តីសន្និដ្ឋាន និង/ឬអនុសាសន៍ទាំងអស់ដែលមាននៅក្នុងរបាយការណ៍នេះ ឆ្លុះបញ្ចាំងពីគោលជំហររបស់រដ្ឋដែលដាក់អនុសាសន៍ និង/ឬរបស់រដ្ឋដែលស្ថិតក្រោមការពិនិត្យ។ សេចក្តីសន្និដ្ឋាន និង/ឬអនុសាសន៍ទាំងនេះ មិនគួរត្រូវបានបកស្រាយថា ត្រូវបានអនុម័តដោយក្រុមការងារទាំងមូលនោះឡើយ។

*****&*****

# ឧបសម្ព័ន្ធ

## *សមាសភាពនៃគណៈប្រតិភូ*

គណៈប្រតិភូកម្ពុជាត្រូវបានដឹកនាំដោយ ឯ.ឧ កែវ រ៉េមី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងមានសមាសភាពជាសមាជិកចូលរួមដូចខាងក្រោម៖

- ឯ.ឧ. នៃ សំអុល តំណាងអចិន្ត្រៃយ៍/ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
- ឯ.ឧ អ៊ិត រ៉ាឌី អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- ឯ.ឧ. កត្តា អន សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- ឯ.ឧ. ប៊ុន ហុន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
- ឯ.ឧ. ម៉ម វណ្ណៈ រដ្ឋលេខាធិការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ឯ.ឧ. ម៉ែន វិចិត្រ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ឯ.ឧ. ងឿន ចន្ទ័លីន ប៉ូឡែន អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន
- ឯ.ឧ. ជិន ម៉ាលីន អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌
- ឯ.ឧ. សុខ សូកាន អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ឯ.ឧ. ស៊ឹម វីរៈ ទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- លោក គឹម សុវណ្ណឌី អនុប្រធាននាយកដ្ឋាននៃបេឡាជាតិសន្តិសុខសង្គម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- លោកស្រី ផាត់ ឌីណា អនុប្រធានការិយាល័យ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- លោក ឡុង សុខន ទីប្រឹក្សា
- លោកយ៉ង់ សុខា ទីប្រឹក្សា
- លោក ង៉ែត ធនសេរីបណ្ឌិត ទីប្រឹក្សា
- លោកវ៉េង វុទ្ធា លេខាទី២
- លោក សុខា ផាតដូរ៉ា លេខាទី២
- លោកស្រី ម៉េង មុនីរ័ត្ន មន្ត្រីបេសកកម្មតំណាងអចិន្ត្រៃយ៍